

# អាន និងរៀន ដើម្បីកសាងអនាគត

Sipar

## របាយការណ៍សកម្មភាពប្រចាំឆ្នាំ ២០២២

# មាតិកា


សាររបស់ក្រុមការងារអង្គការស៊ីប៉ា ៣
អំពីអង្គការស៊ីប៉ា ៤
កម្មវិធីក្នុងសាលារៀន ៦
កម្មវិធីអប់រំ និងអំណានសម្រាប់ទាំងអស់គ្នា ៨
កម្មវិធីអភិវឌ្ឍយុវជន ១៤
កម្មវិធីបោះពុម្ពផ្សាយ ១៧
ព្រឹត្តិការណ៍សំខាន់ៗ ២០
សកម្មភាពអប់រំផ្សេងៗ ក្រៅពីសៀវភៅ ២២
ដៃគូរបស់យើង ២៤
សង្ខេបចំណាយប្រចាំឆ្នាំ ២០២២ ២៥
ផែនការសម្រាប់ឆ្នាំ ២០២៣ ២៦


LABEL IDEAS
L'EXIGENCE
*en action*

អង្គការស៊ីប៉ាបានទទួលស្លាក IDEAS កាលពីដើមឆ្នាំ ២០២៣។ ការទទួលស្គាល់នេះបញ្ជាក់ពីឧត្តមានុវត្តលើអភិបាលកិច្ច ហិរញ្ញវត្ថុ និងប្រសិទ្ធភាពសកម្មភាព។



# សាររបស់អង្គការស៊ីប៉ា

អង្គការស៊ីប៉ាបានប្រារព្ធខួបទី៤០ឆ្នាំនៅក្នុងឆ្នាំ២០២២! ស៊ីប៉ាត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៨២ នៅទីក្រុងវ៉ែកសៃ ( Versailles ) នៃប្រទេសបារាំង ដើម្បីផ្តល់ជំនួយដល់ជនភៀសខ្លួនពីប្រទេសនៃតំបន់អាស៊ីអាគ្នេយ៍។ ស៊ីប៉ាចាប់ផ្តើមបេសកកម្មរបស់ខ្លួននៅក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រការអប់រំកម្រិតបឋមសិក្សា និងពង្រឹងវប្បធម៌អំណាន។ បន្ទាប់មក ស៊ីប៉ាក៏បានបង្កើតកម្មវិធីលើកកម្ពស់ការយល់ដឹង និងការអប់រំសម្រាប់ប្រជាជនកម្ពុជាទាំងអស់ ជាពិសេសកុមារ និងក្រុមជនងាយរងគ្រោះ។

នៅតាមសាលារៀននានាក្នុងប្រទេសកម្ពុជា មានបណ្ណាល័យប្រមាណ៣០០ហើយ ដែលត្រូវបានសាងសង់ឡើងក្រោមជំនួយពីស៊ីប៉ា និងដាក់ឱ្យសិស្សានុសិស្សប្រើប្រាស់។ អង្គការស៊ីប៉ាបន្តគាំទ្របណ្ណាល័យទាំងនេះតាមរយៈការផ្គត់ផ្គង់សៀវភៅ ការបណ្តុះបណ្តាលលើការគ្រប់គ្រងបណ្ណាល័យ ការនិទានរឿង និងវគ្គអប់រំលើការយល់ដឹងអំពីបញ្ហាសង្គម និងបរិស្ថាន។

បណ្ណាល័យចល័តចំនួន១៤ កំពុងចរាចរនៅក្នុងខេត្តចំនួន៧ នៃប្រទេសកម្ពុជា ក៏ដូចជាក្នុងរាជធានីភ្នំពេញ និងតំបន់ជុំវិញ ដើម្បីផ្តល់សកម្មភាពអំណាន និងអប់រំ។ ដើម្បីផ្តល់សៀវភៅជាអចិន្ត្រៃយ៍ដល់អ្នកអាន យើងបានបង្កើតបណ្ណាល័យខ្នាតតូចចំនួន៧៩ កន្លែង ដែលគ្រប់គ្រងដោយអ្នកស្ម័គ្រចិត្តនៅតាមភូមិ។ លើសពីនេះ បណ្ណាល័យនៅក្នុងរោងចក្រកាត់ដេរចំនួន២៥ ដែលផ្តល់សេវាកម្មដល់កម្មករ-កម្មការិនីក្នុងវិស័យវាយនភណ្ឌ នៅតែបន្តគ្រប់គ្រងដោយរោងចក្រទាំងនោះដោយផ្ទាល់។

កម្មវិធីក្នុងពន្ធនាគារនៅតែបន្ត និងរហូតមកដល់ពេលនេះ ពន្ធនាគារទាំង២៨ទូទាំងប្រទេសត្រូវបានបំពាក់ដោយបណ្ណាល័យហើយ។ ថ្មីៗនេះ គម្រោងសាកល្បងមួយត្រូវបានដាក់ឱ្យដំណើរការនៅក្នុងពន្ធនាគារចំនួនប្រាំ ដើម្បីបញ្ជ្រាបការអប់រំបែបឌីជីថលដោយមិនភ្ជាប់បណ្តាញអ៊ីនធឺណិត ដើម្បីគាំទ្រជនជាប់ឃុំក្នុងការរៀបចំខ្លួនក្នុងការធ្វើសមាហរណកម្ម និងការអភិវឌ្ឍខ្លួនរបស់ពួកគេ។

គម្រោងអភិវឌ្ឍយុវជនបានឈានចូលឆ្នាំទីពីរហើយ។ យើងបានបង្កើតបណ្ណាល័យ និងជ្រុងតម្រង់ទិសវិជ្ជាជីវៈចំនួនប្រាំបី នៅក្នុងវិទ្យាល័យ ដើម្បីលើកស្ទួយការតម្រង់ទិសវិជ្ជាជីវៈនៃសិស្សានុសិស្ស និងគាំទ្រការចុះឈ្មោះទទួលស្គាល់ជាផ្លូវការនៃអង្គការសហគមន៍យុវជនមូលដ្ឋានចំនួន១៥ នៅតាមឃុំរបស់ពួកគេ។ ក្រុមការងារស៊ីប៉ាក៏បានរៀបចំការបណ្តុះបណ្តាលដើម្បីពង្រឹងជំនាញរបស់បណ្ណារក្ស និងសមាជិកនៃអង្គការសហគមន៍យុវជនមូលដ្ឋាន និងគាំទ្រការបង្កើតវេទិកាការងារនៅវិទ្យាល័យ ឬតាមអ៊ីនធឺណិត ដើម្បីជួយសិស្សក្នុងការតម្រង់ទិសវិជ្ជាជីវៈ។

ជាចុងក្រោយ ក្រុមការងារបោះពុម្ពផ្សាយនៅតែបន្តលើកកម្ពស់ការអាន និងការអប់រំ តាមរយៈការបោះពុម្ពចំណងជើងថ្មីៗជារៀងរាល់ឆ្នាំ។ ក្នុងឆ្នាំ២០២២ ស៊ីប៉ាបានបោះពុម្ពសៀវភៅថ្មីចំនួន២៤ចំណងជើង ហើយបច្ចុប្បន្ននេះកាតាឡុករបស់ស៊ីប៉ាមាន២៧០ចំណងជើងហើយ។

ស៊ីប៉ាបានពង្រឹងសកម្មភាពរបស់ខ្លួនអស់រយៈពេល៤០ឆ្នាំហើយ ហើយយើងនឹងបន្តពង្រីកបេសកកម្មរបស់ខ្លួនក្នុងការលើកកម្ពស់ការអាន និងការអប់រំសម្រាប់ទាំងអស់គ្នា ការគាំទ្រផ្នែកអប់រំ និងការអភិវឌ្ឍយុវជនកម្ពុជានៅក្នុងតំបន់ដែលជួបការលំបាកបំផុត។

យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមិត្តរួមការងារ ដៃគូសហការ និងម្ចាស់ជំនួយទាំងអស់ ដែលនៅតែបន្តផ្តល់ការគាំទ្រដល់ពួកយើងក្នុងការចូលរួមអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា។

ក្រុមការងារអង្គការស៊ីប៉ា

# អំពីអង្គការស៊ីប៉ា

## អាន និងរៀនដើម្បីកសាងអនាគត

អង្គការស៊ីប៉ាគឺជាអង្គការសាមគ្គីភាពអន្តរជាតិ ដែលផ្តោតសកម្មភាពលើវិស័យអប់រំនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩១មក។ អង្គការស៊ីប៉ារួមចំណែកយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងនឹងអនក្ខរភាព និងចូលរួមអភិវឌ្ឍវិស័យអំណានសម្រាប់ទាំងអស់គ្នា តាមរយៈការពង្រឹងបណ្តាញបណ្ណាល័យចល័តនិងអចល័ត នៅតាមសាលារៀន សហគមន៍ជនបទ តំបន់ជាយក្រុងភ្នំពេញ ឡូតដ្ឋ រោងចក្រកាត់ដេរ មន្ទីរពេទ្យ និងពន្ធនាគារជាដើម។ ដោយមានកិច្ចសហការយ៉ាងល្អជាមួយក្រសួងអប់រំ យុវជន និងកីឡា អាជ្ញាធរមូលដ្ឋាន និងសហគមន៍ សមាគមក្នុងស្រុក និងអន្តរជាតិ អង្គការស៊ីប៉ាបានធ្វើការផ្សព្វផ្សាយ និងចែកចាយសៀវភៅទូទាំងប្រទេស តាមរយៈការអនុវត្តកម្មវិធីប្រកបដោយភាពច្នៃប្រឌិត។

លើសពីនេះ ដោយឃើញភាពទន់ខ្សោយនៃវិស័យបោះពុម្ពផ្សាយនៅកម្ពុជា និងកង្វះខាតសៀវភៅអានជាភាសាខ្មែរ អង្គការស៊ីប៉ាបានពង្រីកបេសកកម្មរបស់ខ្លួននៅឆ្នាំ២០០០ ដោយបង្កើតកម្មវិធីបោះពុម្ពផ្សាយសៀវភៅជាភាសាខ្មែរសម្រាប់កុមារ យុវវ័យ និង មនុស្សពេញវ័យ។ អង្គការស៊ីប៉ាកំពុងរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់លទ្ធភាពទទួលបានចំណេះដឹង ការអប់រំ និងជួយដល់កុមារក្នុងការរៀនអក្សរនៅក្នុងបរិបទនៃកម្ពុជាដែលមានអនក្ខរជន១២.៣%។




## អំណានសម្រាប់ទាំងអស់គ្នា

- បណ្ណាល័យចល័តចំនួន១៤ ធ្វើសកម្មភាពនៅតាមទីតាំងចំនួន១០៤ ក្នុងរាជធានីខេត្តចំនួន៧ ៖ ដោយប្រើរថយន្តចំនួន៩ តុកតុកចំនួន៣ កាណូតចំនួន១ និងម៉ូតូចំនួន១
- បណ្ណាល័យចំនួន២៨ នៅក្នុងពន្ធនាគារ និងមណ្ឌលអប់រំកែប្រែនៅក្នុងខេត្តចំនួន២៥ រួមទាំងក្នុងរាជធានីភ្នំពេញ
- បណ្ណាល័យសហគមន៍ចំនួន១៧ នៅក្នុងខេត្តចំនួន៣
- បណ្ណាល័យខ្នាតតូចនៅតាមមន្ទីរពេទ្យចំនួន១៩ នៅក្នុងខេត្តចំនួន១៨ រួមទាំងក្នុងរាជធានីភ្នំពេញ
- បណ្ណាល័យមណ្ឌលសិក្សាសម្រាប់កម្មករ កម្មការិនីរោងចក្រកាត់ដេរចំនួន២៥ កំពុងដំណើរការក្នុងខេត្តចំនួន៩ រួមទាំងរាជធានីភ្នំពេញ
- បណ្ណាល័យខ្នាតតូចចំនួន៣៤ នៅតាមផ្ទះអ្នកស្ម័គ្រចិត្តក្នុងសហគមន៍

## កម្មវិធីក្នុងសាលារៀន

- បណ្ណាល័យសាលារៀនមានចំនួន៣០៧ នៅទូទាំង២៥រាជធានីខេត្ត
- បណ្ណាល័យខ្នាតតូចចំនួន៤៥ នៅក្នុងខេត្តចំនួន៦

## កម្មវិធីការងារស្ម័គ្រចិត្តរបស់យុវជនដើម្បីការអភិវឌ្ឍសហគមន៍

- អង្គការសហគមន៍យុវជនមូលដ្ឋាន ចំនួន១៥ នៅខេត្តព្រៃវែង និងក្រចេះ
- បណ្ណាល័យ និងជ្រុងតម្រង់ទិសវិជ្ជាជីវៈចំនួន៨
- បណ្ណាល័យខ្នាតតូចចំនួន៣៣ ដែលគ្រប់គ្រងដោយយុវជនស្ម័គ្រចិត្ត

## កម្មវិធីបោះពុម្ពផ្សាយ

- សៀវភៅថ្មីចំនួន ២៤ ចំណងជើងក្នុងឆ្នាំ២០២២ ដែលសរុបមាន២៧០ចំណងជើងចាប់ពីឆ្នាំ២០០១
- សៀវភៅ ៣លាន ២សែនក្បាលចាប់ពីឆ្នាំ២០០១
- វគ្គបណ្តុះបណ្តាលចំនួនជាង៨៣ចាប់ពីឆ្នាំ២០០៤មក

**៤០ ឆ្នាំ**

បុគ្គលិកខ្មែរសរុប

ចំនួន **៦២** នាក់

សមាជិក

ក្រុមប្រឹក្សាភិបាល

**១៣** នាក់

គ្របដណ្តប់ទូទាំង

**២៥** រាជធានី ខេត្ត

អ្នកទទួលផល

**+៣៤០ ០០០** នាក់

តាមរយៈ **៦៤០** បណ្ណាល័យ

## ចក្ខុវិស័យ

បន្ទាប់ពីសង្គ្រាមជាច្រើនទសវត្ស សង្គមកម្ពុជាត្រូវការពលរដ្ឋប្រកប ដោយចំណេះដឹង។ **ការអប់រំជាកត្តា** ចាំបាច់សម្រាប់កសាងអនាគត។

## បេសកកម្ម

ចូលរួមចំណែកក្នុងការ**អភិវឌ្ឍធនធានមនុស្ស** នៅកម្ពុជា ជាពិសេសសម្រាប់ប្រជាជនដែល គ្មានឱកាស តាមរយៈការផ្សព្វផ្សាយការអាន និងវិធីអប់រំផ្សេងៗ។

## គុណតម្លៃ

- ឯករាជ្យ
- តម្លាភាព
- គោរពបុគ្គល និងវប្បធម៌ចម្រុះ
- ការផ្ទេរចំណេះដឹង
- នវានុវត្តន៍
- ស្វយ័តភាព

## សកម្មភាពរបស់អង្គការស៊ីប៉ាចែកជា៤កម្មវិធីសំខាន់។ ៖



**កម្មវិធី ក្នុងសាលារៀន**



**កម្មវិធីអប់រំ និងអំណាន សម្រាប់ទាំងអស់គ្នា**



**កម្មវិធី អភិវឌ្ឍយុវជន**



**កម្មវិធី បោះពុម្ពផ្សាយ**




*អង្គការស៊ីប៉ាផ្តោតសកម្មភាពលើគោលដៅអភិវឌ្ឍន៍ប្រកប ដោយចីរភាព៣ គឺ ៖*

៤ - ការអប់រំប្រកបដោយគុណភាព

១០ - កាត់បន្ថយវិសមភាព

១៧ - ភាពជាដៃគូដើម្បីសម្រេចគោលដៅ

**យើងក៏បានចូលរួមចំណែកសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរ ភាពផ្សេងទៀតដែរ តាមរយៈកម្មវិធីផ្សេងៗរួមមាន ៖**

៣ - សុខភាព និងសុខុមាលភាពមាំមួន ( តាមរយៈកម្មវិធី អប់រំស្តីពីសុខភាព )

៥ - សមភាពយេនឌ័រ ( កម្មវិធីគាំទ្រការងារស្ម័គ្រចិត្តរបស់ យុវជន និងកម្មវិធីអប់រំស្តីពីស្ទីម )

៨ - ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច( កម្មវិធីបណ្ណាល័យ ក្នុងរោងចក្រ )

១២ - ការប្រើប្រាស់ និងការផលិតប្រកបដោយការទទួលខុសត្រូវ ( តាមរយៈកម្មវិធីអប់រំស្តីពី បរិស្ថាន )

១៦ - សន្តិភាព យុត្តិធម៌ និងពង្រឹងស្ថាប័នដៃគូ ( កម្មវិធីបណ្ណាល័យក្នុងពន្ធនាគារ )



គាំទ្រការអនុវត្តគោលនយោបាយជាតិសម្រាប់អភិវឌ្ឍបណ្ណាល័យសាលារៀននៅកម្រិតមត្តេយ្យ បឋមសិក្សា និងមធ្យមសិក្សា។

# កម្មវិធីក្នុងសាលារៀន



# កម្មវិធីក្នុងសាលារៀន

## មត្តេយ្យសិក្សា ៖ បណ្ណាល័យខ្នាតតូច និងការបណ្តុះបណ្តាល

*បរិបទ ៖ នៅកម្ពុជា មានកុមារតែម្នាក់ប៉ុណ្ណោះក្នុងចំណោមបីនាក់អាយុចន្លោះពី៣ ទៅ៥ឆ្នាំ ដែលបានចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យ ចំណែកឯសាលាមត្តេយ្យសហគមន៍វិញក៏នៅមានចំនួនតិចនៅឡើយ។ សាលាមត្តេយ្យភាគច្រើនជាសាលាមត្តេយ្យសហគមន៍ដែលគ្រប់គ្រងដោយអាជ្ញាធរ ព្យាបាល និងក្រុមប្រឹក្សាឃុំសង្កាត់ ហើយជួបប្រទះនូវកង្វះខាតសម្ភារៈ។ គ្រូមត្តេយ្យសិក្សាក៏មិនទាន់បានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ បើទោះបីការងាររបស់ពួកគាត់មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍ និងបណ្តុះការអានរបស់កុមារ។*

នៅឆ្នាំ២០២២ ស៊ីប៉ាបានបង្កើតបណ្ណាល័យខ្នាតតូចថ្មីចំនួន១៩ នៅក្នុងសាលាមត្តេយ្យសហគមន៍ដែលមានទីតាំងជុំវិញទ្បតដ្ឋក្បែររាជធានីភ្នំពេញ និងក្នុងខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ ដើម្បីជំរុញឱ្យមានសកម្មភាពអំណានក្នុងកម្មវិធីសិក្សាថ្នាក់ដំបូង។ បណ្ណាល័យខ្នាតតូចនីមួយៗមានសៀវភៅពី ១០០ ទៅ ៥០០ក្បាល។

បណ្ណាល័យខ្នាតតូចដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់ការអានរបស់កុមារនៅតាមសហគមន៍ ដោយផ្តល់ឱ្យពួកគេនូវលទ្ធភាពទទួលបានសៀវភៅប្រចាំថ្ងៃ។ បណ្ណារក្សចល័តរបស់ស៊ីប៉ាបានផ្តល់ការបណ្តុះបណ្តាលអំពីការគ្រប់គ្រងបណ្ណាល័យខ្នាតតូចដល់មន្ត្រីអប់រំនៅក្នុងមត្តេយ្យសហគមន៍ និងអ្នកគ្រប់គ្រងស្ម័គ្រចិត្តនៃបណ្ណាល័យខ្នាតតូចនីមួយៗ។

## បឋមសិក្សានិងមធ្យមសិក្សា ៖ ការសាងសង់អគារសិក្សា បណ្ណាល័យ បណ្ណាល័យខ្នាតតូច និងការបណ្តុះបណ្តាល

*បរិបទ ៖ នៅឆ្នាំ ១៩៩៣ អង្គការស៊ីប៉ាបានចាប់ផ្តើមកម្មវិធីបណ្ណាល័យសាលាដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡាលើបីផ្នែកសំខាន់ៗ ៖ អភិវឌ្ឍបណ្តាញបណ្ណាល័យចំនួន ៣០០ បង្កើតការិយាល័យទទួលបន្ទុកបណ្ណាល័យសាលាដោយពង្រឹងស្តង់ដារបណ្ណាល័យ និងបណ្តុះបណ្តាលបណ្ណារក្សសាលាបឋមសិក្សា។ គម្រោងនេះបានអភិវឌ្ឍ និងរីកចម្រើន ដែលឈានទៅដល់ការធ្វើស្ថាប័នភាវូបនីយកម្មនៃកម្មវិធីនេះ ទៅកម្រិតថ្នាក់ជាតិ។*

នៅឆ្នាំ២០១៩ អង្គការស៊ីប៉ាបានផ្តល់សៀវភៅចំនួន១០០ក្បាល ដល់បណ្ណាល័យនីមួយៗក្នុងបណ្តាញបណ្ណាល័យទាំង៣០០ ដើម្បីឱ្យបណ្ណាល័យទាំងនេះមានសៀវភៅថ្មី ព្រមទាំងលើកទឹកចិត្តបណ្ណារក្ស ដោយបន្ថែមក្រុមសៀវភៅក្នុងបណ្ណាល័យ និងជាពិសេសបំពេញតម្រូវការដល់អ្នកអាន។ ដោយមានការគាំទ្រពីម្ចាស់ជំនួយជាច្រើន យើងបានផ្តល់សៀវភៅដល់សាលាចំនួន៣៥ នៅឆ្នាំ២០២២ ហើយយើងនឹងបន្តផ្តល់សៀវភៅដល់បណ្ណាល័យចំនួន៣៤ បន្ថែមទៀតសម្រាប់ឆ្នាំ២០២៣។ យើងក៏បានបង្កើតបណ្ណាល័យថ្មីចំនួន៧ និងបណ្ណាល័យខ្នាតតូចចំនួន១៨ ដែរ។

នៅឆ្នាំ២០២២នេះ ស៊ីប៉ាបានសម្ពោធអគារទីមួយនៅអនុវិទ្យាល័យកសាងក្នុងឃុំចង្ក្រង់ ស្រុកចិត្របុរី ខេត្តក្រចេះ! អគារសិក្សាថ្មីដែលមានប្រាំបន្ទប់ និងបណ្ណាល័យមួយត្រូវបានដាក់ឱ្យប្រើប្រាស់ ដើម្បីបំពេញតម្រូវការអប់រំរបស់សិស្សានុសិស្សប្រមាណ៤០០នាក់ ក្នុងឆ្នាំសិក្សាថ្មីនេះ។ អង្គការស៊ីប៉ាក៏បានដាក់ឱ្យប្រើប្រាស់នូវបណ្ណាល័យខ្នាតតូចចំនួនពីរនៅក្នុងគ្រឹះស្ថានមធ្យមសិក្សាដែរ ដែលបន្ទប់នីមួយៗត្រូវបានបំពាក់ដោយសៀវភៅចំនួន ៣០០ក្បាល ស្របតាមតម្រូវការរបស់សិស្សានុសិស្សកម្រិតមធ្យមសិក្សា។






ជួយដល់ប្រជាជនដែលជួបការលំបាក ឱ្យមានទម្លាប់អាន ដោយពង្រីកឱកាសទទួលបានសៀវភៅ ព័ត៌មាន និងការអប់រំ ដែលជាកត្តាចាំបាច់ក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។

# កម្មវិធីអប់រំ និងអំណានសម្រាប់ទាំងអស់គ្នា



# បណ្ណាល័យចល័ត

*បរិបទ ៖ លទ្ធភាពទទួលបានសៀវភៅ និងចំណេះដឹងសម្រាប់សហគមន៍នៅជាយក្រុងភ្នំពេញ និងជនបទនៅមានកម្រិតនៅឡើយ ដោយខ្វះហេដ្ឋារចនាសម្ព័ន្ធអប់រំ ដូចជាបណ្ណាល័យសាធារណៈជាដើម។ ចាប់តាំងពីឆ្នាំ ២០០០ មក កម្មវិធីបណ្ណាល័យចល័តរបស់ស៊ីប៉ាបានចាប់ផ្តើមដំណើការដោយនាំយកសកម្មភាពអំណាន សំណេរ និងសៀវភៅទៅដល់កុមារ ព្រមទាំងផ្តល់ការអប់រំ និងការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសង្គមផ្សេងៗ។*

បណ្ណាល័យចល័តទាំង ១៤ រួមមានបណ្ណាល័យរថយន្តចំនួន៩ បណ្ណាល័យតុកតុកចំនួន៣ បណ្ណាល័យកាណូតចំនួន១ និងបណ្ណាល័យម៉ូតូចំនួន១។ បណ្ណាល័យចល័តទាំង ១៤ នេះកំពុងធ្វើសកម្មភាពនៅតាមទីតាំងជាង ១០៤ កន្លែងជារៀងរាល់សប្តាហ៍ នៅតាមខេត្តចំនួន៧ និងបានផ្តល់ផលដល់អ្នកអានជាង ១៥,០០០ នាក់។ សកម្មភាពទូទៅរបស់បណ្ណាល័យចល័តចាប់ផ្តើមដោយការនិទានរឿង និងអំណានសេរី ល្បែងអប់រំ និងច្នៃប្រឌិត និងបញ្ចប់ដោយការខ្ចីសងសៀវភៅ។ ថ្មីៗនេះ ក្រុមការងារបណ្ណាល័យចល័តបានរៀបចំថ្នាក់បំប៉នរៀងរាល់សប្តាហ៍ លើមុខវិជ្ជាសំខាន់ៗដូចជាភាសាខ្មែរ និងគណិតវិទ្យា។

ស៊ីប៉ាបានបង្កើតបណ្ណាល័យខ្នាតតូចនៅតាមភូមិ ដើម្បីធានាបាននូវនិរន្តរភាពនៃបេសកកម្ម ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកស្ម័គ្រចិត្តក្នុងសហគមន៍។ បណ្ណាល័យខ្នាតតូចចំនួន ៣៤ ដែលមានសៀវភៅសរុបចំនួន ២៦០០០ ក្បាល ត្រូវបានដាក់ឱ្យដំណើរការ និងគ្រប់គ្រងដោយអ្នកស្ម័គ្រចិត្តក្នុងសហគមន៍។ ក្រុមការងារស៊ីប៉ាផ្តល់ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ការគ្រប់គ្រងបណ្ណាល័យ និងបច្ចេកទេសផ្នែកនិទានរឿង ក៏ដូចជាការលើកកម្ពស់ការយល់ដឹងលើប្រធានបទផ្សេងៗ។

ស្របជាមួយសកម្មភាពអំណាន ក្រុមការងាររបស់យើងក៏រៀបចំវគ្គយល់ដឹងលើប្រធានបទសំខាន់ៗ ៖ សុខភាព និងអាហារូបត្ថម្ភ សុវត្ថិភាពចរាចរណ៍ ការអប់រំកម្មវិធីបរិយាបន្នសម្រាប់អ្នករស់នៅជាមួយពិការភាព យោគៈ និងសមាធិ បរិស្ថាន និងស្ទីម (STEAM) - វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា។ បណ្ណាល័យចល័តចំនួនបួនមានឯកទេសលើប្រធានបទទាំងនេះ ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងចំណោមកុមារ ក្មេងជំទង់ និងមនុស្សពេញវ័យ។

លើសពីនេះ យើងផ្ទេរចំណេះដឹងទៅដល់អ្នកបន្តវេននៅក្នុងវិស័យអំណាន និងអប់រំ ដោយបណ្តុះបណ្តាលគ្រូ និងសិស្សានុសិស្សនៃអនុវិទ្យាល័យទន្លេកន្ទឹលក្នុងខេត្តកំពង់ស្ពឺ លើការគ្រប់គ្រងបណ្ណាល័យ រៀបចំសកម្មភាពអំណាន ហើយបានផ្តួចផ្តើមគំនិតសិស្សក្នុងការគ្រប់គ្រងស្រេ្តសដោយសហការជាមួយអង្គការក្នុងស្រុកដែលមានឯកទេសខាងចិត្តវិទ្យា។



*“តួនាទីរបស់បណ្ណារក្សចល័តមានសារៈសំខាន់ណាស់ក្នុងការជួយកុមារអភិវឌ្ឍទម្លាប់អាន។ បណ្ណាល័យចល័តក៏បង្កើតបរិយាកាសរីករាយផងដែរ នៅពេលដែលក្មេងៗមកជុំគ្នាដើម្បីស្តាប់ អាន និងលេងជាមួយគ្នា។ យើងកំពុងអភិវឌ្ឍសកម្មភាពរបស់យើង ដោយធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ ដើម្បីផ្តល់ការអប់រំដែលមានភាពបត់បែនទៅតាមតម្រូវការរបស់កុមារទាំងអស់។”*

**ចន សុភក្តិ**
បណ្ណារក្សចល័តស៊ីប៉ា

រថយន្តបណ្ណាល័យចល័ត ៩

បណ្ណាល័យតុកតុក ចល័ត ៣

បណ្ណាល័យម៉ូតូ ចល័ត ១

បណ្ណាល័យកាណូត ចល័ត ១

អ្នកទទួលផល ១៥ ០០០នាក់

១០៤ ទីតាំង

បណ្ណាល័យខ្នាតតូច ៣៤




# បណ្ណាល័យចល័តសម្រាប់ប្រជាជនដែលងាយរងគ្រោះ

***បរិបទ ៖*** *ប្រជាជនកម្ពុជាប្រមាណ ១៨% រស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ ពោលគឺមានចំណូលតិចជាងពីរដុល្លារកន្លះក្នុងមួយថ្ងៃសម្រាប់មនុស្សម្នាក់។ ប្រជាជនក្រីក្រភាគច្រើនរស់នៅក្នុងតំបន់មិនទាន់រៀបរយតាមជាយក្រុងភ្នំពេញ និងនៅតំបន់ជនបទ តំបន់បឹងទន្លេសាប និងតំបន់ភ្នំ។*

ចាប់តាំងពីឆ្នាំ ២០១៣ មក ដោយមានការគាំទ្រដោយសមាគម RESPEK អង្គការស៊ីប៉ាបានធ្វើការជាមួយជនជាតិភាគតិចក្នុងខេត្តរតនគិរី ដើម្បីលើកកម្ពស់ការអាន និងផ្តល់ការគាំទ្រផ្នែកអប់រំដល់កុមារ។ គ្រួសារជនជាតិភាគតិចទំពួន និងចារ៉ាយ បានចាកចេញពីជីវិតប្រពៃណីជាអ្នកបរបាញ់នៅក្នុងព្រៃ ដើម្បីក្លាយជាកសិករ និងជាអ្នកចិញ្ចឹមសត្វ ហើយការផ្លាស់ប្តូរនេះទាមទារឱ្យមានការសម្របខ្លួនចូលក្នុងបរិបទជីវិតថ្មី។ បណ្ណាល័យម៉ូតូស៊ីប៉ាត្រូវបានប្តូរមកជាបណ្ណាល័យតុកតុក ដែលបំពាក់ដោយសៀវភៅ និងល្បែងអប់រំ ហើយកំពុងធ្វើសកម្មភាពនៅក្នុងភូមិដាច់ស្រយាលទាំង១២ នៃស្រុកបរកែវ។ បណ្ណារក្សដែលចេះពីរភាសា ខ្មែរ-ទំពួន កំពុងផ្តល់ការគាំទ្រយ៉ាងសំខាន់ដល់កុមារផ្នែកអំណាន និងការអប់រំ ដើម្បីពង្រឹងការសិក្សារបស់ពួកគេជាភាសាខ្មែរ។

អង្គការស៊ីប៉ាបានផ្តួចផ្តើមគម្រោងដំបូងសម្រាប់ការអភិវឌ្ឍអំណាន និងការប្រយុទ្ធប្រឆាំងនឹងអនក្ខរភាពក្នុងចំណោមគ្រួសារកម្មករនៅតាមឡឥដ្ឋក្នុងឆ្នាំ២០១៨។ ឡឥដ្ឋនីមួយៗមានគ្រួសាររស់នៅជាមធ្យមចំនួន ៤០ និងមានប្រជាជនសរុបជាមធ្យមប្រមាណ ១៥០នាក់ ដែលក្នុងនោះ ៥០ នាក់មានអាយុក្រោម ១៨ ឆ្នាំ។ គ្រួសារកម្មករទាំងនេះរស់នៅក្នុងភាពក្រីក្រខ្លាំង ហើយកុមារមានលទ្ធភាពទទួលបានការសិក្សាតិចតួចបំផុត។ ក្នុងឆ្នាំ២០២០ យើងបានដាក់ឱ្យដំណើរការជាទៀងទាត់នូវបណ្ណាល័យចល័តចំនួនពីរ ដើម្បីធ្វើសកម្មភាពរៀងរាល់សប្តាហ៍នៅក្នុងឡឥដ្ឋចំនួន៤ ដែលបច្ចុប្បន្ននេះបានកើនដល់ឡឥដ្ឋចំនួន១២ហើយ ដោយធ្វើសកម្មភាពជាមួយកុមារចំនួន ៤០០នាក់ និងឪពុកម្តាយរបស់ពួកគេ និងជួយដល់ការសិក្សារបស់កុមារដែលមានអាយុពី៦ ទៅ១២ឆ្នាំ។

យើងក៏ជួយដល់គ្រួសារដែលរស់នៅក្នុងស្ថានភាពមិនច្បាស់លាស់ ក្នុងតំបន់មិនទាន់រៀបរយតាមជាយក្រុងភ្នំពេញ។ ប្រជាជនទាំងនេះមានលទ្ធភាពតិចតួចក្នុងការទទួលបានការអប់រំ និងសេវាសុខភាព ដែលជាហេតុឱ្យជួបប្រទះនឹងអត្រាអនក្ខរភាពខ្ពស់។ អង្គការស៊ីប៉ាបានដាក់ឱ្យដំណើរការបណ្ណាល័យតុកតុក២ សម្រាប់បម្រើដល់តំបន់មិនទាន់រៀបរយចំនួន១៤ និងសាលាអប់រំពិសេសចំនួន២។ យើងបានដាក់ឱ្យដំណើរការបណ្ណាល័យតុកតុកទីមួយនៅឆ្នាំ២០១៩ និងបណ្ណាល័យតុកតុកទីពីរនៅឆ្នាំ២០២១ ដោយសហការជាមួយអង្គការពិភពកុមារ និងអភិវឌ្ឍន៍ ដើម្បីលើកកម្ពស់អំណាន ផ្តល់ការគាំទ្រផ្នែកអប់រំ និងលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសង្គម។

អង្គការស៊ីប៉ាបានដាក់ឱ្យប្រើប្រាស់បណ្ណាល័យទូកដំបូងបំផុតនៅលើបឹងទន្លេសាបក្នុងឆ្នាំ២០១៩ សម្រាប់អ្នករស់នៅលើបឹង និងភូមិបណ្តែតទឹកដែលមានភាពដាច់ស្រយាល និងពិបាកក្នុងការទៅដល់។ កម្រិតអប់រំក្នុងតំបន់នេះនៅមានកង្វះខាតនៅឡើយ ៖ កុមារមួយភាគបួនមិនបានទៅសាលាដោយសារខ្វះមធ្យោបាយធ្វើដំណើរ។ បណ្ណាល័យទូកធ្វើសកម្មភាពរៀងរាល់សប្តាហ៍ក្នុងភូមិគោលដៅចំនួនបី និងភូមិជាប់គ្នាចំនួនបីក្នុងឃុំផ្លូវទូក។ គម្រោងនេះជួយប្រយុទ្ធប្រឆាំងនឹងការបោះបង់ការសិក្សា។ លើសពីនេះទៀត ក្រុមការងាររបស់យើងរៀបចំវគ្គយល់ដឹងអំពីបញ្ហាសង្គមជាច្រើនដងក្នុងមួយឆ្នាំជាមួយមនុស្សពេញវ័យនៅក្នុងភូមិទាំងនេះ។



> *បណ្ណារក្សចល័តរបស់អង្គការស៊ីប៉ាមានវិធីអានសៀវភៅយ៉ាងពីរោះ ហើយខ្ញុំតែងតែស្រមើស្រមៃទៅតាមសាច់រឿងៗ នៅពេលដែលបានចូលរួមជាមួយបណ្ណាល័យចល័ត ខ្ញុំតែងតែចូលចិត្តខ្ចីសៀវភៅអក្សរសិល្ប៍ខ្មែរមកអាននៅផ្ទះៗ ឪពុកម្តាយរបស់ខ្ញុំចូលចិត្តបណ្ណាល័យចល័តណាស់ ហើយពួកគាត់ពិតជាលើកទឹកចិត្តខ្ញុំឱ្យចូលរួម និងរៀនៗ*

**ថង សុខរិន**

អាយុ ១៣ឆ្នាំ អ្នកចូលរួមសកម្មភាពបណ្ណាល័យចល័តស៊ីប៉ានៃខេត្តតាកែវ



# បណ្ណាល័យមណ្ឌលសិក្សាក្នុងរោងចក្រកាត់ដេរ

*បរិបទ ៖ បច្ចុប្បន្នវិស័យរោងចក្រកាត់ដេរនៅកម្ពុជា មានកម្មករ-កម្មការិនីធ្វើការចំនួនប្រមាណ ៧០០ ០០០នាក់ ដែលក្នុងនោះ ៨៥% ជាស្ត្រីដែលមានវ័យក្រោម២៨ឆ្នាំ។ ដោយសារខ្វះលទ្ធភាពទទួលបានការអប់រំមូលដ្ឋាន ប្រហែល ២៥% នៃកម្មករ-កម្មការិនីរោងចក្រកាត់ដេរជាអនក្ខរជន។*

ចាប់តាំងពីឆ្នាំ២០១៣មក អង្គការស៊ីប៉ាបានដាក់ឱ្យដំណើរការបណ្ណាល័យមណ្ឌលសិក្សាក្នុងរោងចក្រកាត់ដេរចំនួន៣២ ក្នុងគោលបំណងចូលរួមកាត់បន្ថយភាពងាយរងគ្រោះរបស់កម្មករ-កម្មការិនី ស្របនឹងការពង្រឹងសមត្ថភាពរបស់ពួកគេដែលរួមចំណែកដល់ផលិតកម្មការងារ។ គម្រោងនេះបានឈានដល់ការបញ្ចប់នៃដំណាក់កាលទីពីររបស់ខ្លួននៅឆ្នាំ២០២១ ហើយរោងចក្រចំនួន២៥នៅតែបន្តរក្សាដំណើរការបណ្ណាល័យមណ្ឌលសិក្សាដោយឯករាជ្យ ដោយដាក់ឱ្យប្រើប្រាស់នូវបណ្ណាល័យរបស់គេដល់បុគ្គលិកជាង ៧៥ ០០០នាក់ និងមានអ្នកប្រើប្រាស់ប្រហែល ៧ ០០០នាក់ក្នុងមួយខែ។

បណ្ណាល័យមណ្ឌលសិក្សាក្នុងរោងចក្រកាត់ដេរ ផ្តល់ឱ្យកម្មករ-កម្មការិនីនូវសៀវភៅអាន ថ្នាក់អក្ខរកម្ម និងការយល់ដឹងអំពីប្រធានបទសង្គមសំខាន់ៗ ដែលធ្វើឡើងនៅកន្លែងធ្វើការរបស់គេដោយផ្ទាល់ ដើម្បីឱ្យពួកគេបង្កើតទម្លាប់នៃការអាន និងរៀនដោយខ្លួនឯង។ ក្រោមការលើកទឹកចិត្តពីសមាគម GMAC និង UNESCO បណ្ណាល័យមណ្ឌលសិក្សាទាំងនេះរៀបចំថ្នាក់អក្ខរកម្មសម្រាប់បុគ្គលិកជាប្រចាំ។

ឥឡូវនេះ យើងបន្តធ្វើការជាមួយរោងចក្រក្នុងនាមជាទីប្រឹក្សាបច្ចេកទេស ដើម្បីរក្សាដំណើរការបណ្ណាល័យមណ្ឌលសិក្សា និងផ្តល់ការគាំទ្រសម្រាប់ការគ្រប់គ្រងបណ្ណាល័យ និងការលើកកម្ពស់ការអានតាមតម្រូវការ ៖

- ផ្តល់ដំបូន្មានដល់បណ្ណារក្សអំពីការប្រើប្រាស់កម្មវិធីគ្រប់គ្រងបណ្ណាល័យ PMB និងការប្រមូលទិន្នន័យ។
- លើកទឹកចិត្ត និងផ្តល់ជំនួយក្នុងការរៀបចំប្រតិបត្តិការផ្សព្វផ្សាយអំណាន ក្នុងកម្មវិធី «សៀវភៅចល័ត»។
- ផ្លាស់ប្តូរបទពិសោធន៍ និងគំនិតផ្តួចផ្តើមដោយបណ្តាញបណ្ណារក្សដែលជាសមាជិកនៃរោងចក្រទាំង២៥។
- បោះពុម្ព និងចែកចាយសៀវភៅណែនាំលើការគ្រប់គ្រងបណ្ណាល័យនៅក្នុងរោងចក្រកាត់ដេរដល់រោងចក្រកាត់ដេរទាំងអស់។



*“គម្រោងក្នុងរោងចក្រកាត់ដេរមានប្រយោជន៍ខ្លាំងណាស់សម្រាប់ទាំងកម្មករ-កម្មការិនី និងនិយោជក។ គម្រោងនេះបានផ្តល់ធនធានសំខាន់ៗសម្រាប់កម្មករដើម្បីអភិវឌ្ឍចំណេះដឹងទូទៅ ក៏ដូចជាទម្លាប់សិក្សាដោយខ្លួនឯងដែលត្រូវបានលើកទឹកចិត្តដោយការអាន និងអនុវត្តអ្វីដែលពួកគេបានរៀននៅកន្លែងធ្វើការ។ ស៊ីប៉ានៅតែជាដៃគូបច្ចេកទេសសម្រាប់រោងចក្រដៃគូរបស់យើងទាំងអស់។”*

**ទេព បុប្ផា**
ជំនួយការបច្ចេកទេសគម្រោងនៅអង្គការស៊ីប៉ា

**បណ្ណាល័យចំនួន ២៥**

**កំពុងបម្រើដល់កម្មករ-កម្មការិនីចំនួន ៧៥ ០០០ នាក់**

**កម្មករ ៧ ០០០នាក់ ប្រើប្រាស់បណ្ណាល័យមណ្ឌលសិក្សាទៀងទាត់**



# បណ្ណាល័យ និងកម្មវិធីអប់រំក្នុងពន្ធនាគារ

*បរិបទ ៖ ទណ្ឌិតភាគច្រើនមកពីមជ្ឈដ្ឋានដែលជួបការលំបាក ឬមិនមានឱកាស មានកម្រិតការអប់រំ និងស្ថានភាពសេដ្ឋកិច្ចសង្គមទាប និងមិនមានជំនាញវិជ្ជាជីវៈត្រឹមត្រូវ។ ជាការពិត ស្ថាប័នរដ្ឋបានផ្តល់ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ ប៉ុន្តែឱកាសដើម្បីអភិវឌ្ឍការអប់រំ និងធ្វើសមាហរណកម្មចូលសង្គមសម្រាប់ទណ្ឌិតនៅមានកម្រិតនៅឡើយ។*

## កម្មវិធីអភិវឌ្ឍន៍បណ្តាញបណ្ណាល័យពន្ធនាគារជាតិ

អង្គការស៊ីប៉ាបានពង្រឹងបណ្តាញថ្នាក់ជាតិនៃបណ្ណាល័យ-មជ្ឈមណ្ឌលអប់រំនៅក្នុងពន្ធនាគារចាប់តាំងពីឆ្នាំ២០១២ ដោយមានការគាំទ្រពីសហភាពអឺរ៉ុប ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ និងមូលនិធិ Pierre Bellon ដោយសហការជាមួយអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ និងដៃគូផ្សេងទៀត។ គម្រោងនេះមានគោលបំណងចូលរួមផ្តល់ការអប់រំ និងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនជាប់ឃុំ។

គម្រោងនេះបានឈានដល់ដំណាក់កាលទីបី ( មួយដំណាក់កាល = ៣ឆ្នាំ ) ហើយក៏ជាដំណាក់កាលចុងក្រោយ និងត្រូវបានបញ្ចប់នៅក្នុងខែឧសភា ឆ្នាំ ២០២២ ខណៈបណ្ណាល័យទាំង២៨ ត្រូវបានគ្រប់គ្រងដោយពន្ធនាគារផ្ទាល់ដោយមានការគាំទ្រពីអគ្គនាយកដ្ឋានពន្ធនាគារ។ ពន្ធនាគាររាជធានីភ្នំពេញគឺជាពន្ធនាគារទី២៨ ដែលត្រូវបានបំពាក់ និងដាក់ឱ្យប្រើប្រាស់នូវបណ្ណាល័យនៅដើមឆ្នាំ២០២២ សម្រាប់ជនជាប់ឃុំ។

វគ្គរៀបចំសមាហរណកម្មត្រូវបានធ្វើឡើងដោយដៃគូក្នុងស្រុករបស់ស៊ីប៉ាចំនួនពីរគឺ អង្គការមិត្តសំឡាញ់នៅក្នុងពន្ធនាគារម២ កណ្តាល ព្រៃវែង និងស្វាយរៀង ដោយមានជនជាប់ឃុំចូលរួមចំនួន១០០នាក់។ អង្គការម្លប់តាប៉ាង ដែលត្រូវផ្អាកសកម្មភាពក្នុងពន្ធនាគារខេត្តព្រះសីហនុដោយសារជំងឺឆ្លងកូវីដ១៩ បានផ្តល់ជំនួយផ្នែកចិត្តសាស្ត្រដល់យុវជនញៀនថ្នាំជាច្រើនរយនាក់ ដើម្បីផ្តល់ឱកាសឱ្យពួកគេស្តារនីតិសម្បទាឡើងវិញ និងជៀសផុតពីការឃាត់ខ្លួន។

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា កំពុងអនុវត្តគោលនយោបាយជាតិសម្រាប់អក្ខរកម្មក្នុងពន្ធនាគារ ដោយមានការគាំទ្រពីអង្គការស៊ីប៉ាផ្នែកអប់រំដល់គ្រូបង្រៀនដែលជាមន្ត្រីពន្ធនាគារ និងជំនួយជាសម្ភារៈដល់សិស្ស។ នៅឆ្នាំ២០២២ ថ្នាក់អក្ខរកម្មចំនួន២១ បានផ្តល់អត្ថប្រយោជន៍ដល់ជនជាប់ឃុំចំនួន៤២៧នាក់។

យើងបានរៀបចំសិក្ខាសាលាថ្នាក់ជាតិក្នុងខែកក្កដា ឆ្នាំ២០២២ ក្រោមអធិបតីភាពនៃឯកអគ្គរដ្ឋទូតបារាំង និងអគ្គនាយកពន្ធនាគារ ដែលបានចូលរួមដោយប្រធានពន្ធនាគារទាំង២៨នាក់ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនៃគម្រោងដែលបានដាក់ឱ្យដំណើរការចាប់តាំងពីឆ្នាំ២០១២ និងសម្តោជជាផ្លូវការនូវកម្មវិធីអប់រំថ្មីដែលនឹងបន្តសកម្មភាពនៅក្នុងពន្ធនាគារបន្ទាប់ពីគម្រោងចាស់នេះចប់ទៅ ( ខែមីនា ឆ្នាំ២០២២ ដល់ខែកុម្ភៈ ឆ្នាំ២០២៥ )។

បណ្ណាល័យ
២៨
ជនជាប់ឃុំចំនួន
៣៨ ០០០ នាក់

អ្នកអាន
៨ ០០០
នាក់ក្នុងមួយខែ

ប្រព័ន្ធឧបករណ៍ឌីជីថល
នៅក្នុងបណ្ណាល័យចំនួន ៥
មានអ្នកទទួលផល ២៥០ នាក់

អ្នករៀន
ថ្នាក់អក្ខរកម្ម
៤២៧ នាក់

អ្នកចូលរួមវគ្គ
បណ្តុះបណ្តាល
វិជ្ជាជីវៈ ១០០ នាក់



# បណ្ណាល័យ និងកម្មវិធីអប់រំក្នុងពន្ធនាគារ

## កម្មវិធីអប់រំនៅក្នុងពន្ធនាគារ ( ខែមីនា ឆ្នាំ២០២២ ដល់ខែកុម្ភៈ ឆ្នាំ២០២៥ )

ដោយមានបទពិសោធន៍រយៈពេល១០ឆ្នាំក្នុងការអភិវឌ្ឍបណ្តាញបណ្ណាល័យជាតិក្នុងពន្ធនាគារ និងការយល់ដឹងពីតម្រូវការ និងសារៈសំខាន់នៃការអប់រំ ការបណ្តុះបណ្តាល និងការរៀបចំសមាហរណកម្មសម្រាប់ជនជាប់ឃុំ អង្គការស៊ីប៉ាបានដាក់ឱ្យដំណើរការគម្រោងថ្មីប្រកបដោយភាពច្នៃប្រឌិត និងការអប់រំប្រកបដោយប្រសិទ្ធភាពនៅក្នុងពន្ធនាគារ ដោយសហការជាមួយអគ្គនាយកដ្ឋានពន្ធនាគារ និងក្រសួងអប់រំ យុវជន និងកីឡា និងគាំទ្រគម្រោងដោយមូលនិធិ Pierre Bellon។

គម្រោងអប់រំឌីជីថលដោយមិនភ្ជាប់បណ្តាញអ៊ីនធឺណិតត្រូវបានដាក់ដំណើរការសាកល្បងនៅក្នុងបណ្ណាល័យពន្ធនាគារចំនួនប្រាំ ហើយយើងនឹងពង្រីកដល់ពន្ធនាគារទាំង២៨ នៅត្រឹមខែកុម្ភៈ ឆ្នាំ២០២៥។ ពន្ធនាគារនីមួយៗនឹងត្រូវបានបំពាក់ដោយ Nomad Lab ដែលជាប្រព័ន្ធឧបករណ៍ឌីជីថលមិនភ្ជាប់បណ្តាញអ៊ីនធឺណិត ដែលបង្កើតឡើងដោយអង្គការដៃគូ Passerelles numériques។ កុំព្យូទ័រយួរដៃ ត្រូវបានផ្តល់ជូនដល់ពន្ធនាគារនីមួយៗ ជាមួយនឹងឯកសារអំណានប្រមាណ៨០០ច្បាប់ ឯកសារវីដេអូអប់រំចំនួន ២៦០ និងកម្មវិធីឌីជីថលមិនភ្ជាប់បណ្តាញអ៊ីនធឺណិតចំនួន១២០ សម្រាប់ជនជាប់ឃុំ។ កម្មវិធីនេះមានគោលបំណងពង្រឹងការរៀនសូត្ររបស់ជនជាប់ឃុំ និងគាំទ្រក្នុងការរៀបចំខ្លួនធ្វើសមាហរណកម្មឡើងវិញ។ ចាប់តាំងពីគម្រោងនេះត្រូវបានបង្កើតឡើង ជនជាប់ឃុំជាង២៥០នាក់ហើយបានទទួលផលពីធនធានដែលបានបង្កើតឡើងនៅក្នុងប្រព័ន្ធឧបករណ៍ឌីជីថលមិនភ្ជាប់បណ្តាញអ៊ីនធឺណិតទាំងនេះ។

សេវាប្រឹក្សាយោបល់ និងខ្ចីសងសៀវភៅនៅក្នុងពន្ធនាគារទាំង២៨ នៅតែដំណើរការសម្រាប់ជនជាប់ឃុំទាំងអស់។ បណ្ណាល័យស្ទើរតែទាំងអស់ត្រូវបានគ្រប់គ្រងដោយកម្មវិធី PMB ហើយក្រុមរបស់យើងនឹងបន្តផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងការបណ្តុះបណ្តាលដល់មន្ត្រីពន្ធនាគារ និងបណ្ណារក្សជនជាប់ឃុំតាមតម្រូវការរបស់ពួកគេ។

ក្រុមការងារអង្គការស៊ីប៉ានឹងបន្តគាំទ្រផ្នែកគរុកោសល្យសម្រាប់មន្ត្រីពន្ធនាគារដែលត្រូវបានបណ្តុះបណ្តាលដោយក្រសួងអប់រំ យុវជន និងកីឡា លើការបង្រៀនកម្មវិធីអក្ខរកម្មថ្មី សម្រាប់អ្នកសិក្សារហូតដល់ចប់ថ្នាក់ទីប្រាំមួយនៃបឋមសិក្សា។

លើសពីនេះ យើងក៏កំពុងបញ្ជ្រាបសកម្មភាពវប្បធម៌ និងច្នៃប្រឌិត ៖ សិក្ខាសាលាស្តីពីការនិពន្ធលើកទីមួយ ដែលដឹកនាំដោយអ្នកសារព័ត៌មានស្ម័គ្រចិត្តខ្មែរ-ស្វីស បានធ្វើឡើងជាមួយជនជាប់ឃុំស្ត្រីចំនួនប្រាំពីរនាក់នៃពន្ធនាគារ ម២ ដោយមានក្រុមបោះពុម្ពស៊ីប៉ាជាអ្នកត្រួតពិនិត្យស្នាដៃដើម្បីផលិត និងបោះពុម្ពផ្សាយ។ សិក្ខាសាលាអក្សរសាស្ត្រ និងសិល្បៈផ្សេងៗទៀតនឹងប្រព្រឹត្តទៅនៅក្នុងពន្ធនាគារចំនួន៤ផ្សេងទៀត។

ក្រុមការងារស៊ីប៉ានឹងសហការជាផ្លូវការជាមួយទីភ្នាក់ងារជាតិមុខរបរ និងការងារ។ អង្គការស៊ីប៉ា អគ្គនាយកដ្ឋានពន្ធនាគារ និងពន្ធនាគារនានា បានទាក់ទងទីភ្នាក់ងារការងារខេត្ត ( មជ្ឈមណ្ឌលការងារ ) ក្នុងខេត្តចំនួន៥ ដើម្បីជានាការរៀបចំសមាហរណកម្ម សង្គម-វិជ្ជាជីវៈរបស់ជនជាប់ឃុំ។ ភ្នាក់ងារនៃមជ្ឈមណ្ឌលការងារនឹងរៀបចំការបណ្តុះបណ្តាលដល់ជនជាប់ឃុំមុនការដោះលែងលើជំនាញត្រៀមផ្សេងៗសម្រាប់ការធ្វើសមាហរណកម្មរបស់ពួកគេ ដូចជា ការមានទំនាក់ទំនងល្អ ការដោះស្រាយបញ្ហា ទំនុកចិត្តលើខ្លួនឯង ការស្វែងរកការងារ ទីផ្សារការងារ ការសរសេរប្រវត្តិរូបសង្ខេប ការសម្ភាសន៍ ទំនាក់ទំនងជាមួយអ្នកគ្រប់គ្រង និងសហការី។ល។

> *ខ្ញុំរីករាយណាស់ដែលបានចូលរួមក្នុងកម្មវិធីការអប់រំក្នុងពន្ធនាគារ ព្រោះឥឡូវនេះខ្ញុំអាចរៀនបច្ចេកវិទ្យាថ្មីៗបានតាមរយៈឧបករណ៍ឌីជីថល។ នៅពេលដែលខ្ញុំត្រូវបានដោះលែង ខ្ញុំគិតថាខ្ញុំនឹងអាចប្រើប្រាស់ឧបករណ៍ទាំងនេះបាន។*
>
> ជនជាប់ឃុំនៅពន្ធនាគារខេត្តកំពត



គាំទ្រដល់សិស្សមធ្យមសិក្សានៅតំបន់ជនបទ និងសមាជិកនៃអង្គការសហគមន៍យុវជនមូលដ្ឋាន ឱ្យមានឱកាសទទួលបានការងារកាន់តែប្រសើរ និងក្លាយជាតួអង្គចូលរួមសាមគ្គីអភិវឌ្ឍសង្គម និងការអប់រំក្នុងសហគមន៍។

# កម្មវិធីអភិវឌ្ឍយុវជន



# លើកស្ទួយលទ្ធភាពទទួលបានការងារ និងភាពជាពលរដ្ឋសកម្មរបស់យុវជន

*បរិបទ ៖ កម្ពុជាមានយុវជនអាយុពី១៥ ទៅ២៩ឆ្នាំ ប្រមាណ ៤៣% នៃប្រជាជនសរុប។ លទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាពនៅមានកម្រិតនៅឡើយនៅតំបន់ដាច់ស្រយាល ហើយអត្រាបោះបង់ការសិក្សាក៏មានកម្រិតខ្ពស់ចំពោះយុវជនដែលទើបចូលក្នុងទីផ្សារការងារ ដោយភាគច្រើនមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ បច្ចុប្បន្ន ស៊ីប៉ាកំពុងបង្កើតគម្រោងរយៈពេលបីឆ្នាំដែលមានឈ្មោះថា «ការលើកស្ទួយលទ្ធភាពទទួលបានការងារ និងភាពជាពលរដ្ឋសកម្មរបស់យុវជន» ដែលបានចាប់ផ្តើមក្នុងខែតុលា ឆ្នាំ២០២១ ដោយទទួលបានការគាំទ្រពីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ AFD និងមានការសហការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើនលទ្ធភាពទទួលបានការងារ និងពង្រឹងការចូលរួមអភិវឌ្ឍសង្គមរបស់យុវជន។*

## បណ្ណាល័យ និងជ្រុងតម្រង់ទិសវិជ្ជាជីវៈ

នៅឆ្នាំ២០១៩ អង្គការស៊ីប៉ាបានសាកល្បងបង្កើតបណ្ណាល័យ និងជ្រុងតម្រង់ទិសវិជ្ជាជីវៈនៅក្នុងវិទ្យាល័យចំនួនបី។ ផ្អែកលើបទពិសោធន៍នេះ យើងបានចាប់ផ្តើមគម្រោងរយៈពេលបីឆ្នាំដើម្បីប្រែក្លាយបណ្ណាល័យវិទ្យាល័យចំនួន១៣ ផ្សេងទៀត ឱ្យទៅជាបណ្ណាល័យ មានជ្រុងតម្រង់ទិសវិជ្ជាជីវៈ។ យើងនឹងធ្វើការរៀបចំបណ្ណាល័យទាំងនេះ និងបំពាក់គ្រឿងសង្ហារិមបន្ថែម ព្រមទាំងឯកសារ និងឧបករណ៍ឌីជីថល (Nomad Lab) បង្កើតឡើងដោយអង្គការដៃគូ Passerelles numériques ដែលផ្តល់ជូនសិស្សានុសិស្សនូវឧបករណ៍ឌីជីថលដើម្បីជួយតម្រង់ទិសសិក្សា និងពង្រឹងជំនាញឌីជីថលរបស់ពួកគេ។

មកទល់នឹងពេលនេះ ស៊ីប៉ាបានរៀបចំបណ្ណាល័យ និងជ្រុងតម្រង់ទិសវិជ្ជាជីវៈចំនួន៨ ដែលកន្លែងនីមួយៗមានឯកសារជាង៨០០ច្បាប់ និងកុំព្យូទ័រចំនួន៨ (Chromebooks) ជាមួយនឹងកម្មវិធីជាង១១០ដោយភ្ជាប់ និងមិនភ្ជាប់អ៊ីនធឺណិត ដើម្បីគាំទ្រដល់ការសិក្សា និងតម្រង់ទិសសម្រាប់សិស្សមធ្យមសិក្សា។ យើងបានបណ្តុះបណ្តាលបណ្ណារក្ស ទីប្រឹក្សាក្រុមប្រឹក្សាគ្រប់គ្រងសាលា និងមន្ត្រីនៃក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងប្រើប្រាស់ធនធានពហុព័ត៌មាននៃបណ្ណាល័យមណ្ឌលតម្រង់ទិសវិជ្ជាជីវៈ។

ដើម្បីជាជំនួយបន្ថែមក្នុងការតម្រង់ទិសសិស្ស ស៊ីប៉ាបានរៀបចំ «វេទិកាការងារ» ម្តង ឬពីរដងក្នុងមួយឆ្នាំនៅក្នុងវិទ្យាល័យនីមួយៗ ដើម្បីណែនាំសិស្សអំពីឱកាសសិក្សា និងវិជ្ជាជីវៈ ព្រមទាំងវិធីសាស្ត្រល្អបំផុតដើម្បីរៀបចំអនាគតរបស់ពួកគេបន្ទាប់ពីបញ្ចប់ការសិក្សា។ «វេទិកាការងារ» ចំនួន៨ត្រូវបានរៀបចំឡើងនៅក្នុងសាលាមធ្យមសិក្សា និងវេទិកាការងារចំនួន៣តាមប្រព័ន្ធអនឡាញ។ សិស្សវិទ្យាល័យជាង ៥០០ នាក់នៅក្នុងសាលានីមួយៗបានជួបពិភាក្សាជាមួយនឹងគ្រឹះស្ថានសិក្សា និងក្រុមហ៊ុនឯកជនមកពីវិស័យផ្សេងៗគ្នាដែលមានវត្តមាននៅក្នុងវេទិកាទាំងនេះ។



*«បណ្ណាល័យមណ្ឌលតម្រង់ទិសវិជ្ជាជីវៈនៅវិទ្យាល័យសោមធំ ផ្តល់អត្ថប្រយោជន៍ជាច្រើនដល់សិស្ស និងអនុញ្ញាតឱ្យយើងស្វែងរកវិជ្ជាជីវៈ ការងារ និងជំនាញផ្សេងៗទៀត។ យើងក៏អាចស្រាវជ្រាវអំពីមហាវិទ្យាល័យ និងអាជីពនៅពេលយើងរៀបចំសម្រាប់ការសិក្សាបន្ត បន្ទាប់ពីបញ្ចប់ការសិក្សានៅមធ្យមសិក្សា។»*

**រចំ បុប្ផា**
សិស្សវិទ្យាល័យសោមធំ

**បណ្ណាល័យមណ្ឌលតម្រង់ទិសវិជ្ជាជីវៈចំនួន៨ បំពាក់ដោយ NomadLab**

**វេទិកាការងារចំនួន ១១ មានអ្នកចូលរួម ៥ ០០០ នាក់**

**បណ្តុះបណ្តាលគ្រូបង្រៀនចំនួន ៦៥ នាក់ (ស្ត្រី២០ នាក់)**



# លើកស្ទួយលទ្ធភាពទទួលបានការងារ និងភាពជាពលរដ្ឋសកម្មរបស់យុវជន

## ភាពជាពលរដ្ឋសកម្មរបស់យុវជនដើម្បីអភិវឌ្ឍសហគមន៍

គម្រោងនេះក៏មានបេសកកម្មដើម្បីពង្រឹង និងពង្រីកបណ្តាញនៃអង្គការសហគមន៍យុវជនមូលដ្ឋានចំនួន២៣ ដើម្បីបម្រើដល់ការអភិវឌ្ឍការអប់រំសង្គមរបស់សហគមន៍ និងដើម្បីរចនាឯកសារបោះពុម្ព និងឌីជីថលថ្មីៗសម្រាប់ការអភិវឌ្ឍខ្លួន និងតម្រង់ទិសវិជ្ជាជីវៈរបស់យុវជន។ សមាជិកនៃអង្គការសហគមន៍យុវជនមូលដ្ឋានជាយុវជន ដែលមានអាយុពី១២ ដល់១៨ឆ្នាំ ហើយពួកគេរួមគ្នាអនុវត្តសកម្មភាពស្ម័គ្រចិត្តក្នុងគោលបំណងអភិវឌ្ឍការអប់រំ និងលើកកម្ពស់ការអានដូចជា៖

- សមាជិកគ្រូតូចចំនួន៨៩នាក់ រៀបចំវគ្គបំប៉នភាសាខ្មែរ និងគណិតវិទ្យាពី៤ទៅ៥ដងក្នុង១សប្តាហ៍ ដោយស្របនឹងកម្មវិធីអប់រំថ្នាក់ជាតិដល់កុមារដែលជាសិស្សបឋមសិក្សាចំនួន ៧៣៣នាក់។
- សមាជិកនៃអង្គការសហគមន៍យុវជនមូលដ្ឋានចំនួន៣៧នាក់ ផ្តល់ការខ្ចីសៀវភៅក្នុងសហគមន៍ តាមរយៈបណ្ណាល័យសាក់កាដូដល់អ្នកភូមិប្រមាណ៨០០នាក់ក្នុងមួយខែ។
- បណ្ណាល័យខ្នាតតូចចំនួន៣០ ដែលមាននៅតាមផ្ទះសមាជិកនៃអង្គការសហគមន៍យុវជនមូលដ្ឋាន ស្វាគមន៍កុមារជាង៣០០នាក់ជារៀងរាល់ខែ។
- យុទ្ធនាការអប់រំចំនួន៥ត្រូវបានរៀបចំក្នុងឆ្នាំ២០២២ ដោយមានអ្នកចូលរួមសរុបចំនួន ២ ០០០នាក់ ជុំវិញប្រធានបទដូចជា សុវត្ថិភាពចរាចរណ៍ បរិស្ថាន ការលើកកម្ពស់ការអាន និងការចុះឈ្មោះចូលរៀន។
- បំពាក់ឧបករណ៍ឌីជីថល (NomadLab) ទៅដល់អង្គការសហគមន៍យុវជនមូលដ្ឋានចំនួន១៣ ហើយផ្តល់ការបណ្តុះបណ្តាលសមាជិកក្នុងការគ្រប់គ្រង និងការប្រើប្រាស់ សម្រាប់ជាជំនួយក្នុងការយល់ដឹងអំពីអាជីព ចំណេះដឹងឌីជីថល និងការបង្រៀនកុមារលើកម្មវិធីគណនា និងការអាន។

## ការផលិតសម្ភារៈអប់រំបោះពុម្ព និងឌីជីថល

ដើម្បីបង្កើនឯកសារសម្រាប់ផ្តល់ជូនដល់យុវជន ស៊ីប៉ាកំពុងផលិតសៀវភៅមគ្គុទ្ទេសក៍អាជីព និងការអភិវឌ្ឍខ្លួន និងឧបករណ៍ឌីជីថលអន្តរកម្មថ្មី ដើម្បីចែកចាយបន្តក្នុងរយៈពេលបីឆ្នាំនៃគម្រោងនេះ និងគាំទ្រដល់យុវជនក្នុងការតម្រង់ទិស និងការរៀបចំអនាគតរបស់ពួកគេ។ យើងនឹងបោះពុម្ព និងចែកចាយសៀវភៅចំនួន១១ចំណងជើង ហើយរចនាឧបករណ៍ឌីជីថលចំនួនបួន និងដាក់ឱ្យប្រើប្រាស់ក្នុងកុំព្យូទ័រដែលភ្ជាប់ NomadLabs ។ ក្នុងឆ្នាំ២០២២ ឯកសារមួយចំនួនត្រូវបានបោះពុម្ពរួចជាស្រេច ឬកំពុងស្ថិតក្នុងដំណើរការផលិត៖

- ផលិតផ្ទាំងរូបភាព និងខិត្តប័ណ្ណចំនួន៣០ ០០០ច្បាប់ ដែលមានចំណងជើង «ផ្លូវមួយដើម្បីរៀបចំអនាគតរបស់ខ្ញុំ» ត្រូវបានចែកចាយនៅតាមវិទ្យាល័យ សម្រាប់ការតម្រង់ទិសរបស់សិស្សានុសិស្ស។
- ធ្វើបច្ចុប្បន្នភាព បោះពុម្ពឡើងវិញ និងចែកចាយនូវទស្សនាវដ្តីមុខរបរ «តើអ្នកត្រៀមខ្លួនហើយឬនៅ?» ចំនួនបីចំណងជើង ស្តីពីអាជីពក្នុងវិស័យថាមពលកកើតឡើងវិញ កសិកម្ម និងទេសចរណ៍។
- ក្រុមការងារបោះពុម្ពផ្សាយ បានចាប់ផ្តើមរចនាសៀវភៅមគ្គុទ្ទេសក៍វិជ្ជាជីវៈ និងការដឹកជញ្ជូនតាមផ្លូវអាកាស ដោយសហការជាមួយក្រុមហ៊ុនអាកាសចរណ៍កម្ពុជា ដែលនឹងបោះពុម្ព និងចែកចាយនៅត្រីមាសទី២ ក្នុងឆ្នាំ២០២៣។
- ក្រុមការងារគម្រោងបានចាប់ផ្តើមបង្កើតសៀវភៅមគ្គុទ្ទេសក៍ស្ម័គ្រចិត្តរបស់អង្គការសហគមន៍យុវជនមូលដ្ឋានសម្រាប់ការអភិវឌ្ឍការអប់រំសង្គមក្នុងតំបន់ ដែលនឹងត្រូវបោះពុម្ព និងចែកចាយនៅត្រីមាសទី២ ក្នុងឆ្នាំ២០២៣។





រួមចំណែកដល់ការអប់រំ តាមរយៈការបោះពុម្ពផ្សាយ និងការបណ្តុះបណ្តាលធនធានមនុស្សក្នុងជំនាញផ្សេងៗនៃការងារបោះពុម្ពផ្សាយ និងការផ្តល់សៀវភៅប្រកបដោយគុណភាពខ្ពស់ស្របតាមតម្រូវការ និងចំណង់ចំណូលចិត្តរបស់អ្នកអានខ្មែរដែលជាកុមារ គ្រូបង្រៀន អ្នកអប់រំ និងសាធារណជន។

# កម្មវិធី
# បោះពុម្ពផ្សាយ



# កម្មវិធីបោះពុម្ពផ្សាយ

*បរិបទ ៖ បច្ចុប្បន្ន ចំណាប់អារម្មណ៍លើការអានសៀវភៅនៅតាមសាលារៀន និងតាមផ្ទះមានការកើនឡើងគួរឱ្យកត់សម្គាល់។ ការកើនឡើងនេះអាចសម្គាល់បានដោយមើលឃើញភាពជោគជ័យនៃពិព័រណ៍សៀវភៅកម្ពុជា ដែលបានរៀបចំធ្វើឡើងតាំងពីឆ្នាំ២០១០ ហើយនៅតែបន្តទាក់ទាញអ្នកចូលរួមដែលជាអ្នកអានជារៀងរាល់ឆ្នាំ។ ទោះយ៉ាងណាក៏ដោយ វិស័យបោះពុម្ពនៅកម្ពុជា នៅតែមិនទាន់មានភាពរឹងមាំនៅឡើយទេ ចំណែកឯអាជីពដែលទាក់ទងទៅនឹងវិស័យបោះពុម្ពផ្សាយក៏មិនសូវទទួលបានការយកចិត្តទុកដាក់គ្រប់គ្រាន់ក្នុងសង្គមកម្ពុជា។*

តាំងពីឆ្នាំ២០០១មក អង្គការស៊ីប៉ាបានចាប់ផ្តើមបោះពុម្ពផ្សាយសៀវភៅអប់រំ និងសៀវភៅអក្សរសិល្ប៍ជាភាសាខ្មែរ។ សៀវភៅមួយចំនួនធំត្រូវបានចែកចាយដោយឥតគិតថ្លៃសម្រាប់កម្មវិធីផ្សេងៗដែលគាំទ្រដោយអង្គការស៊ីប៉ា និងអង្គការផ្សេងទៀត ចំណែកសៀវភៅមួយចំនួនទៀតអាចរកបាននៅបណ្ណាគារនានា។ ក្នុងឆ្នាំ២០២២នេះ ក្រុមការងារបោះពុម្ពផ្សាយរបស់យើងបានបង្ហាញនូវភាពមោះមុតដ៏គួរឱ្យកត់សម្គាល់ ដោយរក្សាចង្វាក់ផលិតកម្ម និងភាពច្នៃប្រឌិតយ៉ាងសកម្ម ៖ អង្គការស៊ីប៉ាបានបោះពុម្ពសៀវភៅថ្មីចំនួន២៤ចំណងជើង និងបោះពុម្ពឡើងវិញចំនួន៧៧ចំណងជើង ដែលសរុបទាំងអស់គឺបោះពុម្ពបាន៣,២លានក្បាល ចាប់តាំងពីឆ្នាំ២០០១មក។

ក្រុមការងារស៊ីប៉ាក៏បានបង្កើតក្រុមសៀវភៅថ្មីមួយដែលមានឈ្មោះថា «លោមអារម្មណ៍» ដែលជាក្រុមសៀវភៅអក្សរសិល្ប៍និពន្ធដោយអ្នកនិពន្ធខ្មែរ និងសម្រាប់យុវវ័យ។ ក្រុមសៀវភៅថ្មីនេះផលិតឡើងសម្រាប់អ្នកអានវ័យក្មេង ហើយយើងនឹងបន្តអភិវឌ្ឍសៀវភៅប្រកបដោយគុណភាព ដើម្បីលើកកម្ពស់ការអាននៅកម្ពុជា។

ក្រុមការងារបោះពុម្ពផ្សាយស៊ីប៉ាក៏បណ្តុះបណ្តាលអ្នកស្រលាញ់ការនិពន្ធដោយផ្តល់សិក្ខាសាលាលើការនិពន្ធ និងការបណ្តុះបណ្តាលអំពីបច្ចេកទេសនៃការផលិតសៀវភៅរបស់កុមារ។ នៅក្នុងខែកុម្ភៈ ឆ្នាំ២០២២ យើងបានរៀបចំវគ្គបណ្តុះបណ្តាលមួយជាមួយអ្នកចូលរួមចំនួន៨នាក់ អំពីរបៀបបង្កើតរឿងមួយនៅក្នុងក្រុមសៀវភៅ «ខ្ញុំចេះអាន» ដែលរួមមានស៊េរីសៀវភៅនៃដំណើរផ្សងព្រេងរបស់គិរី និងវារី។ បន្ទាប់ពីការបណ្តុះបណ្តាល យើងបានបង្កើតនិងចេញផ្សាយចំណងជើងថ្មីចំនួន៤។

ដើម្បីអបអរសាទរខួប៤០ឆ្នាំ របស់អង្គការស៊ីប៉ា យើងបានផ្តួចផ្តើមការប្រកួតប្រជែងអ្នកនិពន្ធ និងអ្នកគំនូរសម្រាប់កុមារជាភាសាខ្មែរនៅចុងឆ្នាំ២០២២។ គោលបំណងនៃការប្រកួតប្រជែងនេះ គឺដើម្បីលើកទឹកចិត្តដល់បេក្ខជនឱ្យចាប់ផ្តើមការសរសេររឿងសម្រាប់យុវជន និងបញ្ចេញទេពកោសល្យក្នុងវិស័យនេះ។ បេក្ខជនចំនួន៧៦នាក់ បានចូលរួមក្នុងការប្រកួតប្រជែង ហើយអ្នកឈ្នះចំនួន៤នាក់ត្រូវបានជ្រើសរើស។



*“ខ្ញុំបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការសរសេររឿងរបស់កុមារ ដោយផ្តោតលើស៊េរីសៀវភៅវារី និងគិរី ដែលអង្គការស៊ីប៉ាបានចាប់ផ្តើមបោះពុម្ពផ្សាយនៅឆ្នាំ២០២១។ បន្ទាប់ពីវគ្គបណ្តុះបណ្តាលនេះ ខ្ញុំបានសរសេរសៀវភៅ គិរីលួងប្អូន និងវារីចេះហើរ។ ខ្ញុំសប្បាយចិត្តណាស់ដែលសៀវភៅទាំងពីរនេះត្រូវបានបោះពុម្ព ព្រោះវាជារឿងរបស់កុមារដំបូងបង្អស់ដែលខ្ញុំបាននិពន្ធ។”*

សុិន សុវណ្ណរតនា
អ្នកនិពន្ធអង្គការស៊ីប៉ា





## កម្មវិធីបោះពុម្ពផ្សាយ

# ចំណងជើងសំខាន់ៗដែលបានបោះពុម្ពនៅឆ្នាំ២០២២



### អាស្សូរ

និពន្ធដោយ នរវិទូខ្មែរ លោក អាំង ជូលាន «អាស្សូរ» ជារឿងអក្សរសិល្ប៍បែបប្រវត្តិសាស្ត្រ ដែលនាំអ្នកអានត្រឡប់ទៅសតវត្សទី ១៦ ដើម្បីចូលរួមក្នុងបូជនីយកិច្ចនានានៅតាមប្រាសាទបុរាណ ដំណើរការនៃការធ្វើសិលាចារឹក ការដោះលែងទាសករដោយពួកអភិជន និងជីវិតប្រចាំថ្ងៃរបស់ប្រជាជន។

### ទឹក ធនធានដែលត្រូវថែរក្សា !



ទឹក ធនធានដែលត្រូវថែរក្សា ! (អត្ថបទ ៖ Water Family រូបភាព ៖ Nicolas Trève)។ បោះពុម្ពដំបូងក្នុងឆ្នាំ២០១៩ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយ Vagnon។ សៀវភៅ «ទឹក ធនធានដែលត្រូវថែរក្សា» ដែលបកប្រែជាភាសាខ្មែរ គឺជាសៀវភៅចំណេះដឹង ដែលរួមបញ្ចូលព័ត៌មានអំពីកម្ពុជាផងដែរ និងស្វែងយល់ពីសារៈសំខាន់នៃទឹកចំពោះមនុស្ស សត្វ និងពិភពលោក និងវិធីសាស្ត្រ ដែលយើងអាចការពារទឹក ដែលជាធនធានមានកំណត់។



### យក្សក្នុងព្រៃ

តុបតែងដោយការរចនាយ៉ាងស្រស់ស្អាត និងស្របជាមួយឈុតកំប្លែងៗ «យក្សក្នុងព្រៃ» ជារឿងនិទានបែបបរិស្ថាន ដែលលើកទឹកចិត្ត និងបង្រៀនកុមារអំពីគ្រោះថ្នាក់នៃសំណល់ប្លាស្ទិកក្នុងធម្មជាតិ។

### ប្រអប់សៀវភៅប្រាំក្បាល - នៅក្នុងក្រុមសៀវភៅ «តស់អាន»



ប្រអប់សៀវភៅប្រាំក្បាល ដែលនៅក្នុងក្រុមសៀវភៅ «តស់អាន» គឺជាបណ្តុំនៃរឿងខ្លីៗចំនួនប្រាំ ដែលបោះពុម្ពដោយ l'Ecole des loisirs និងបកប្រែជាភាសាខ្មែរ។ ឪពុកម្តាយអាចអានឱ្យកូនៗស្តាប់ និងស្វែងយល់ពីប្រធានបទដូចជា អារម្មណ៍ ជម្លោះ មិត្តភាព និងក្តីស្រលាញ់។



### ប្រអប់សៀវភៅប្រាំក្បាល - នៅក្នុងក្រុមសៀវភៅ «រឿងដំបូងៗ»

ប្រអប់សៀវភៅប្រាំក្បាល ដែលនៅក្នុងក្រុមសៀវភៅ «រឿងដំបូងៗ» គឺជាការប្រមូលផ្តុំនៃរឿងខ្លីៗចំនួនប្រាំ ដែលត្រូវបានបោះពុម្ពដោយ l'Ecole des loisirs និងបកប្រែជាភាសាខ្មែរ។ ឪពុកម្តាយអាចអានឱ្យកូនៗស្តាប់ ដើម្បីនាំពួកគេស្វែងយល់ពីដំណើរផ្សងព្រេងដ៏គួរឱ្យរំភើប និងប្រកបដោយភាពក្លាហាន និងជំរុញការស្រមើស្រមៃរបស់ពួកគេ។

# ព្រឹត្តិការណ៍សំខាន់ៗ



ខែមករា

## សម្ពោធបណ្ណាល័យទី២៨ នៅពន្ធនាគារាជធានីភ្នំពេញ

ក្រុមការងាររបស់អង្គការស៊ីប៉ាបានចូលរួមក្នុងការបង្កើតបណ្ណាល័យថ្មីនៅក្នុងពន្ធនាគាររាជធានីភ្នំពេញ ដែលជាបណ្ណាល័យទី២៨ នៃគម្រោង «បណ្ណាល័យក្នុងពន្ធនាគារ»។ ក្រៅពីការចែកចាយសម្ភារៈ និងសៀវភៅ ស៊ីប៉ាក៏បានផ្តល់ការបណ្តុះបណ្តាលក្នុងការគ្រប់គ្រងបណ្ណាល័យដោយប្រើកម្មវិធី PMB ដែរ។



ខែកុម្ភៈ

## វេទិកាការងារ នៅវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនព្រៃពោន ខេត្តព្រៃវែង

សកម្មភាពមួយដ៏សំខាន់របស់អង្គការស៊ីប៉ាគឺ «វេទិកាការងារ» ដែលទីបំផុតបានចាប់ផ្តើមម្តងទៀតនៅពេលដែលសាលារៀនបើកដំណើរការឡើងវិញបន្ទាប់ពីការផ្អាករយៈពេលពីរឆ្នាំ នៅវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនព្រៃពោន ក្នុងខេត្តព្រៃវែង។ សិស្សវិទ្យាល័យជាង២៤០នាក់បានមកទស្សនាស្តង់នីមួយៗដើម្បីស្វែងយល់អំពីការសិក្សា និងឱកាសការងារក្រោយបញ្ចប់ការសិក្សា។



ខែមីនា

## សម្ពោធសៀវភៅ «នារីក្លាហាន» នៅវិទ្យាស្ថានបារាំងនៅកម្ពុជា

សៀវភៅ «នារីក្លាហាន» ដែលនិពន្ធដោយលោកស្រី Pénélope Bagieu និងបកប្រែជាភាសាខ្មែរដោយអង្គការស៊ីប៉ា បានសម្ពោធជាផ្លូវការនៅវិទ្យាស្ថានបារាំងនៅកម្ពុជា នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២ ដែលជាផ្នែកមួយនៃការប្រារព្ធទិវាសិទ្ធិនារីអន្តរជាតិ។



ខែមីនា

## វេទិកាការងារ នៅវិទ្យាល័យសោមធំ ខេត្តរតនគិរី

«វេទិកាការងារ» ត្រូវបានរៀបចំឡើងនៅវិទ្យាល័យសោមធំ ក្នុងខេត្តរតនគិរី ដើម្បីផ្តល់ឱកាសដល់សិស្សានុសិស្សជាង ៤០០នាក់ក្នុងការស្វែងយល់អំពីការសិក្សា និងឱកាសការងារ។ ស៊ីប៉ាក៏បានសម្ពោធបណ្ណាល័យថ្មីមួយដែលបំពាក់ដោយប្រព័ន្ធកុំព្យូទ័រ និងជ្រុងតម្រង់ទិស ដើម្បីបំពេញតម្រូវការសិក្សា ស្រាវជ្រាវ និងតម្រង់ទិសរបស់សិស្ស។



ខែមេសា

## ដំណើរទស្សនកិច្ចរបស់ឯកអគ្គរដ្ឋទូតបារាំង លោក JACQUES PELLET ទៅពន្ធនាគារខេត្តកណ្តាល

លោក Jacques Pellet ឯកអគ្គរដ្ឋទូតបារាំងប្រចាំកម្ពុជា លោក Yazid Bensaid នាយកភ្នាក់ងារអភិវឌ្ឍបារាំងប្រចាំអាស៊ីអាគ្នេយ៍ លោកស្រី Ophélie Bourrhis នាយិកាទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ប្រចាំកម្ពុជា ព្រមទាំងតំណាងអង្គការមិត្តសំឡាញ់ អមដោយអង្គការស៊ីប៉ា បានធ្វើទស្សនកិច្ច និងបានសង្កេតការដាក់ឱ្យប្រើប្រាស់បណ្ណាល័យក្នុងពន្ធនាគារខេត្តកណ្តាល។



ខែឧសភា

## សិក្ខាសាលាស្តីពីនិរន្តរភាពនៃសេវាអប់រំ និងការអាននៅក្នុងពន្ធនាគារ

អង្គការស៊ីប៉ាបានរៀបចំសិក្ខាសាលាមួយស្តីពី «និរន្តរភាពនៃសេវាអប់រំ និងការអាននៅក្នុងពន្ធនាគារ» ដែលមានការចូលរួមពីមន្ត្រីចំនួន២៥នាក់ មកពីពន្ធនាគារចំនួន៨។ គោលបំណងនៃសិក្ខាសាលានេះគឺដើម្បីធានានិរន្តរភាពនៃសេវាកម្មបណ្ណាល័យ ថ្នាក់អក្ខរកម្ម និងការធ្វើសមាហរណកម្មអ្នកជាប់ឃុំ។



ខែកក្កដា

## សិក្ខាសាលាបិទគម្រោង «បណ្ណាល័យក្នុងពន្ធនាគារ» និងការសម្ពោធគម្រោងថ្មី «ការអប់រំក្នុងពន្ធនាគារ»

អង្គការស៊ីប៉ាបានរៀបចំសិក្ខាសាលាថ្នាក់ជាតិក្រោមអធិបតីភាពនៃឯកអគ្គរដ្ឋទូតបារាំង និងអគ្គនាយកពន្ធនាគារ និងត្រូវបានចូលរួមដោយប្រធានពន្ធនាគារទាំង២៨នាក់ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនៃគម្រោងរយៈពេលដប់ឆ្នាំនេះក្នុងការអភិវឌ្ឍបណ្តាញបណ្ណាល័យពន្ធនាគារជាតិ និងដាក់ឱ្យដំណើរការជាផ្លូវការនូវគម្រោងអប់រំក្នុងពន្ធនាគារថ្មីរយៈពេលបីឆ្នាំ។



ខែសីហា

## សម្ពោធបណ្ណាល័យថ្មីនៅវិទ្យាល័យទន្លេកន្ទឹល ខេត្តកំពង់ស្ពឺ

បណ្ណាល័យថ្មីមួយត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់នៅវិទ្យាល័យទន្លេកន្ទឹល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដោយមានការសហការជាមួយក្រុមហ៊ុន SABRINA Garment Manufacturing ដើម្បីលើកទឹកចិត្តសិស្សានុសិស្សជាង ៣០០ នាក់ឱ្យអាន និងលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃយោគៈ និងសមាធិ។



ខែកញ្ញា

## វេទិកាការងារ នៅវិទ្យាល័យអង្គរកា ក្នុងខេត្តតាកែវ

វិទ្យាល័យអង្គរកា ខេត្តតាកែវ បានរៀបចំ «វេទិកាការងារ» ដោយសហការជាមួយអង្គការស៊ីប៉ា និងដៃគូនានា។ សិស្សវិទ្យាល័យជាង១ ០០០នាក់ អាចយល់ដឹងអំពីឱកាសសិក្សា និងបណ្តុះបណ្តាលវិជ្ជាជីវៈបន្ទាប់ពីបញ្ចប់ការសិក្សា។



ខែតុលា

## ការប្រកួតប្រជែងអ្នកនិពន្ធ និងអ្នកគំនូរសៀវភៅកុមារ

ដើម្បីអបអរសាទរខួប៤០ឆ្នាំ របស់ស៊ីប៉ា និងបណ្តុះទេពកោសល្យថ្មីៗក្នុងវិស័យបោះពុម្ព «ការប្រកួតប្រជែងអ្នកនិពន្ធ និងអ្នកគំនូរសៀវភៅកុមារ» ត្រូវបានចាប់ផ្តើមពីពាក់កណ្តាលខែតុលារហូតដល់ពាក់កណ្តាលខែវិច្ឆិកា។ អ្នកឈ្នះចំនួនបួននាក់ត្រូវបានជ្រើសរើស និងផ្តល់រង្វាន់ក្នុងឱកាសប្រារព្ធខួបលើកទី៤០របស់ស៊ីប៉ា។



ខែធ្នូ

## សម្ពោធអគារសិក្សាថ្មី និងបណ្ណាល័យ

ក្រោមទឹកចិត្តសប្បុរសធម៌របស់លោកស្រី លី សុវណ្ណា និងមិត្តភក្តិ អគារសិក្សាថ្មី និងបណ្ណាល័យមួយត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២ នៅសាលាបឋមសិក្សាព្រៃពាយ ខេត្តកំពត ដើម្បីស្វាគមន៍សិស្សានុសិស្សចំនួន៥០០នាក់។ អគារសាលារៀនថ្មីមួយទៀត ដែលមានប្រាំបន្ទប់ និងបណ្ណាល័យមួយ ក៏ត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ នៅសាលាមធ្យមសិក្សាកសាង ក្នុងខេត្តក្រចេះ ដើម្បីស្វាគមន៍សិស្សមធ្យមសិក្សាចំនួន៤០០នាក់។



ខែធ្នូ

## ស៊ីប៉ាប្រារព្ធខួប៤០ឆ្នាំ

ដើម្បីអបអរព្រឹត្តិការណ៍ខួប៤០ឆ្នាំតាំងពីការបង្កើតអង្គការមក ស៊ីប៉ាបានបើកទ្វារទទួលសាធារណជន ដើម្បីស្វែងយល់អំពីគម្រោងរបស់អង្គការស៊ីប៉ានៅតាមស្តង់នីមួយៗ ដឹកនាំដោយក្រុមការងារនៃគម្រោងរបស់យើង។ ទូតសុច្ឆន្ទៈ ឪជេណាណា និងបណ្ណារក្សរបស់ស៊ីប៉ា បានរៀបចំសកម្មភាពជុំវិញការអានដល់កុមារ ហើយយើងក៏បានប្រកាសលទ្ធផលនៃ «ការប្រកួតប្រជែងអ្នកនិពន្ធ និងអ្នកគំនូរសៀវភៅកុមារ» ដែរ។

# សកម្មភាពអប់រំផ្សេងៗ ក្រៅពីសៀវភៅ

ក្នុងនាមជាអ្នកជំនាញគរុកោសល្យ ដែលធ្វើការជាមួយជនងាយរងគ្រោះ អង្គការស៊ីប៉ាបានបង្កើតប្រធានបទអប់រំជាច្រើន ក្រោមការសហការជាមួយក្រុមហ៊ុន និងស្ថាប័នសំខាន់ៗមួយចំនួន។ ដោយសហការជាមួយស្ថាប័ន ក្រុមហ៊ុន និងសមាគមក្នុងស្រុក អង្គការស៊ីប៉ាធ្វើសកម្មភាពអប់រំទាំងនេះនៅតាមសហគមន៍ដាច់ស្រយាល តាមរយៈបណ្ណាល័យចល័ត ឬអង្គការសហគមន៍យុវជនមូលដ្ឋាន ឬក្លឹបយុវជន។ ក្នុងប្រធានបទនីមួយៗ អង្គការស៊ីប៉ា បង្កើតល្បែងអប់រំ និងសម្ភារៈបោះពុម្ព ព្រមទាំងសម្រួលសារទៅតាមវ័យរបស់កុមារ និងមនុស្សពេញវ័យ។

គោលបំណងរបស់សកម្មភាពទាំងនេះ គឺដើម្បីផ្លាស់ប្តូរទម្លាប់ និងលើកទឹកចិត្តអ្នកចូលរួមឱ្យផ្សព្វផ្សាយបន្តក្នុងគ្រួសារ និងសហគមន៍របស់ពួកគេ។

## ប្រធានបទអប់រំមួយចំនួនរបស់យើង ៖

### សុខភាព និងអនាម័យ

ដើម្បីអភិវឌ្ឍ និងអនុវត្តគំនិតផ្តួចផ្តើមថ្មីដែលផ្សព្វផ្សាយសារសំខាន់ៗស្តីពីសុខភាព អនាម័យ និង អាហារូបត្ថម្ភទៅដល់ប្រជាជន ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន។

ប្រធានបទ ៖

- ការសម្អាតដៃ
- ការដុសធ្មេញ
- អនាម័យក្នុងការបរិភោគ
- ការបរិភោគទឹកស្អាត
- ការប្រើប្រាស់បង្គន់ត្រឹមត្រូវ
- សារៈសំខាន់នៃការបរិភោគក្រុមអាហារ៣ប្រភេទ វិតាមីនផ្សេងៗ និងរ៉ែ
- ការបំបៅដោះម្តាយ
- ទម្លាប់អនាម័យទប់ស្កាត់ជំងឺឆ្លងកូវីដ១៩



### សុវត្ថិភាពចរាចរណ៍

ដើម្បីចូលរួមចំណែកសកម្មភាពអប់រំស្តីពីច្បាប់ចរាចរណ៍ តាមរយៈវីដេអូ ខិត្តប័ណ្ណ សំណួរចម្លើយ និងល្បែងអប់រំផ្សេងៗ។

ប្រធានបទ ៖

- ច្បាប់ចរាចរណ៍
- សីលធម៌ក្នុងការបើកបរ
- ការពាក់មួកសុវត្ថិភាព
- ការបើកបរលើសល្បឿនកំណត់
- ការប្រើប្រាស់ទូរស័ព្ទក្នុងពេលបើកបរ
- ការបើកបរក្នុងពេលស្រវឹង
- ការពិនិត្យភ្នែកសម្រាប់សុវត្ថិភាពបើកបរ



*"បណ្ណារក្សចល័តរបស់ស៊ីប៉ាបានបង្រៀនខ្ញុំពីការអនុវត្តអនាម័យល្អ ដូចជាការលាងដៃជាប្រចាំ និងការងូតទឹកប្រចាំថ្ងៃ។ អនាម័យគឺជារឿងសំខាន់សម្រាប់ខ្ញុំ ដើម្បីជៀសវាងពីជំងឺលើខ្ញុំ និងក្រុមគ្រួសារ។ សុខភាពមិនល្អនឹងប៉ះពាល់ដល់ការសិក្សារបស់ខ្ញុំ ដូច្នេះខ្ញុំព្យាយាមរក្សាអនាម័យជានិច្ច។"*

**ចាន់ ស្រីឡែន**
អ្នកចូលរួមបណ្ណាល័យចល័តនៅឡតដ្ឋ

*"ការយល់ដឹងអំពីសុវត្ថិភាពចរាចរណ៍មានសារៈសំខាន់ណាស់សម្រាប់សិស្សរបស់ខ្ញុំ។ ដើម្បីមកដល់សាលារៀន ពួកគេត្រូវធ្វើដំណើរតាមផ្លូវជាតិជារៀងរាល់ថ្ងៃដែលមានរថយន្តធំៗជិះកាត់ជាប្រចាំ។ នេះគឺជាហានិភ័យខ្ពស់ចំពោះសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេ។ ខ្ញុំពិតជាលើកទឹកចិត្តសិស្សរបស់ខ្ញុំឱ្យរៀនឱ្យបានច្រើនពីស៊ីប៉ា ព្រោះការយល់ដឹងអំពីសុវត្ថិភាពចរាចរណ៍មិនត្រឹមតែបម្រើពួកគេនៅពេលនេះទេ ប៉ុន្តែនឹងបន្តបម្រើពួកគេរហូតដល់ពេញវ័យ។"*

**ជ័យ សុខា**
គ្រូបង្រៀនសហគមន៍

## បរិស្ថាន

ដើម្បីអប់រំកុមារ និងយុវវ័យក្នុងការអភិវឌ្ឍទម្លាប់ល្អដើម្បីថែរក្សាបរិស្ថាន នៅតាមភូមិស្រុក តាមរយៈសកម្មភាពអប់រំផ្សេងៗ។

**សកម្មភាព ៖**

- វីដេអូអប់រំ និងសំណួរចម្លើយអំពីការប្រើប្រាស់ផ្លាស្ទិក
- សិក្ខាសាលាអំពីស្លាកសញ្ញាហាមឃាត់
- ការអានសៀវភៅទាក់ទងនឹងបរិស្ថាន
- ការកែច្នៃសំរាមឡើងវិញ និងការណែនាំលើរបៀបប្រើប្រាស់ឡើងវិញ
- ការប្រមូលសំរាមតាមប្រភេទ
- ការប្រលងប្រណាំង «ភូមិស្អាតជាងគេ»

## កម្មវិធីស្ទីម (STEAM) ( វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា )

ដើម្បីជួយឱ្យកុមារស្វែងយល់ពីកម្មវិធីស្ទីម តាមរយៈសកម្មភាពអប់រំផ្សេងៗ ក្នុងគោលបំណងបំផុសការស្រលាញ់ និងកំណត់អាជីពក្នុងវិស័យនេះ ដែលជាវិស័យមួយកំពុងតែមានតម្រូវការនៅកម្ពុជា។

**ប្រធានបទ ៖**

- **ជីវៈវិទ្យា** ( សារពាង្គកាយមនុស្ស សត្វ និងរុក្ខជាតិ )
- **ធាតុ** ( ទឹក ខ្យល់ និងកម្តៅ )
- **គណិតវិទ្យា** ( ការគណនា រង្វាស់... )
- **រូបវិទ្យា** ( ទម្ងន់ កម្លាំង ដែកឆក់ )
- **គីមីវិទ្យា** ( សមាសភាព ប្រតិកម្ម )
- **អគ្គិសនី** ( ពិសោធន៍ អគ្គិសនី )
- **វិស្វកម្ម និងមេកានិក** ( កង់ ការសាងសង់ ស្ពាន អគារ យន្តហោះ )
- **វិទ្យាសាស្ត្រកុំព្យូទ័រ** ( ការចាប់ផ្តើមប្រើប្រាស់ថេប្លេតជាមួយល្បែងសិក្សាគណិតវិទ្យា និងការអាន )
- **សិល្បៈ** ( គំនូរ រៀនអំពីពណ៌គោល និងពណ៌បន្ទាប់បន្សំ។ល។ )



*“ បរិស្ថានមានសារៈសំខាន់សម្រាប់ខ្ញុំ ពីព្រោះវាជាកន្លែងដែលយើងរស់នៅ។ ខ្ញុំតែងព្យាយាមមិនចោលសំរាម និងដាក់សំរាមក្នុងធុងឱ្យបានត្រឹមត្រូវ។ ”*

**ឃឿន សុភ័ក្រ**
អាយុ ១១ឆ្នាំ អ្នកចូលរួមបណ្ណាល័យចល័តបរិស្ថាន



*“ ជារៀងរាល់ខែ ខ្ញុំអាចអានសៀវភៅបានប្រហែល១០ក្បាល។ ខ្ញុំពិតជាចូលចិត្តអានសៀវភៅវិទ្យាសាស្ត្រ ព្រោះវាជួយខ្ញុំរៀនអ្វីថ្មីៗអំពីពិភពលោក។ បណ្ណាល័យចល័តស្ទីម ជួយខ្ញុំច្រើនក្នុងការពង្រីកចំណេះដឹងរបស់ខ្ញុំទាក់ទងនឹងវិទ្យាសាស្ត្រ។ ”*

**នីតា**
អាយុ១២ ឆ្នាំ ជាអ្នកចូលរួមក្នុងបណ្ណាល័យចល័តស្ទីម របស់ស៊ីប៉ា

## យោគៈ និងសមាធិ

ដើម្បីជាជំនួយដល់សុខភាពផ្លូវចិត្ត និងសុខភាពទូទៅរបស់កុមារ និងយុវជនតាមរយៈការអនុវត្តសកម្មភាពយោគៈ និងសមាធិ ៖

**អត្ថប្រយោជន៍ ៖**

- ជំនួយដល់ការផ្តោតអារម្មណ៍លើការសិក្សា
- កាត់បន្ថយភាពតានតឹង និងការថប់បារម្ភ
- ជំនួយដង្ហើម បង្កើនថាមពល និងភាពរឹងមាំ
- ជួយឱ្យមានអាកប្បកិរិយាវិជ្ជមាន
- ជួយឱ្យមានភាពរហ័សរហួន និងកម្លាំងសាច់ដុំ
- លើកកម្ពស់សមានចិត្ត និងការយល់ចិត្តក្នុងទំនាក់ទំនងជាមួយអ្នកដទៃ



*“ ការធ្វើយោគៈ និងការតាំងសមាធិ ជួយឱ្យខ្ញុំរឹងមាំមានសុខភាពល្អ ពង្រឹងការចងចាំ និងគេងបានល្អជាងមុនផងដែរ។ ”*

**ស្រីកា**
អាយុ ១៣ឆ្នាំ ចូលរួមក្នុងបណ្ណាល័យចល័តយោគៈ

# ដៃគូរបស់អង្គការស៊ីប៉ា

## ស្ថាប័នដៃគូ

## ស្ថាប័នផ្តល់មូលនិធិ

## អ្នកឧបត្ថម្ភឯកជន និងដៃគូ

## អង្គការដៃគូសហការ

Action Cambodge Handicap, Asia Foundation, Cambodian Library Association, Cambodia Book Publishers Association, Cambodian Women for Peace and Development, Caritas Cambodia, Friends International, GMAC, IBBY, International Committee of the Red Cross, Krousar Thmey, Lycée Français René Descartes, Mith Samlanh, Mlop Tapang, NGO in Education Partnership, Passerelles numériques, Planète Enfants et Développement, Rabbit School, Room to Read, RTI, Save the Children, SVA, This Life Cambodia, Youth Star, EMDR, AZAHAR Foundation

# សង្ខេបចំណាយប្រចាំឆ្នាំ២០២២

## ចំណាយតាមកម្មវិធី (គិតជាដុល្លារ)






$ ៣៨៣ ៤០០ | $ ៤៩១ ៩០០ | $ ៣៦១ ៩០០ | $ ២០៧ ៤០០ | $ ១១៣ ៧០០

**សរុប ៖ $ ១ ៥៥៨ ៣០០**

# ផែនការសម្រាប់ឆ្នាំ២០២៣

## កម្មវិធីក្នុងសាលារៀន

បន្តការសហការជាមួយនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡាតាមរយៈវគ្គបណ្តុះបណ្តាល និងការផ្សព្វផ្សាយការអាន។

### ថ្នាក់មត្តេយ្យ

- បន្តការគាំទ្រលើបណ្ណាល័យខ្នាតតូចក្នុងសាលាមត្តេយ្យសហគមន៍។
- បន្តរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់គ្រូមត្តេយ្យ។

### បណ្ណាល័យបឋមសិក្សា

- ប្រគល់សៀវភៅទៅបណ្ណាល័យចំនួន ៣៤កន្លែង ព្រមទាំងផ្សព្វផ្សាយអំពីសុខភាព អនាម័យ និងបរិស្ថាន។

## កម្មវិធីអប់រំ និងអំណានសម្រាប់ទាំងអស់គ្នា

### បណ្ណាល័យចល័ត

- បន្តអភិវឌ្ឍសកម្មភាពបណ្ណាល័យចល័តលើអំណាន និងបង្កើតសកម្មភាពអប់រំថ្មីៗ។
- បន្តអភិវឌ្ឍសេវាអប់រំលើប្រធានបទផ្សេងៗដូចជា បរិស្ថាន ស្ទីម សុវត្ថិភាពចរាចរណ៍ និងបង្កើតសកម្មភាពអប់រំថ្មី។
- ពង្រឹងបណ្ណាល័យខ្នាតតូចនៅតាមភូមិ។
- ពង្រឹងកិច្ចសហប្រតិបត្តិការរវាងបណ្ណាល័យចល័ត និងសាលាមត្តេយ្យ និងសាលាបឋមសិក្សា។
- រៀបចំផែនការកសាងសមត្ថភាពបុគ្គលិក ដើម្បីឆ្លើយតបនឹងគម្រោងថ្មី និងកសាងសមត្ថភាពរបស់បណ្ណារក្សថ្មី និងជំនួយការបណ្ណាល័យ។
- បង្កើតឧបករណ៍ថ្មីសម្រាប់ការតាមដានសកម្មភាពបណ្ណាល័យចល័តឱ្យកាន់តែមានប្រសិទ្ធភាព។
- សហការជាមួយមន្ទីរអប់រំខេត្ត និងដៃគូអង្គការក្រៅរដ្ឋាភិបាល ដើម្បីបង្កើតប្រសិទ្ធភាពរួមនៃគម្រោងនៅតាមខេត្ត។

### បណ្ណាល័យមណ្ឌលសិក្សា ក្នុងរោងចក្រកាត់ដេរ

- ផ្តល់ជំនួយបច្ចេកទេសដល់បណ្ណាល័យមណ្ឌលសិក្សាដែលកំពុងជួបការលំបាក ទាំងបណ្ណាល័យមណ្ឌលសិក្សាចាស់ និងថ្មីៗ ដោយមានការគាំទ្រពីបណ្ណារក្សចល័ត លើការប្រើប្រាស់កម្មវិធីគ្រប់គ្រង PMB និងការផ្សព្វផ្សាយជ្រុងអំណានសម្រាប់កុមារ។
- អន្តរាគមន៍របស់បណ្ណារក្សចល័តស៊ីប៉ាដើម្បីសហការរៀបចំការផ្សព្វផ្សាយសៀវភៅជាមួយក្រុមការងារបណ្ណាល័យមណ្ឌលសិក្សានៅតាមរោងចក្រកាត់ដេរ។
- ផ្សព្វផ្សាយពីចំណាប់អារម្មណ៍នៃកន្លែងអានទៅកាន់រោងចក្រផ្សេងទៀតតាមរយៈសមាគម GMAC។

### បណ្ណាល័យក្នុងពន្ធនាគារ និងកម្មវិធីអប់រំក្នុងពន្ធនាគារ

- បន្ត និងពង្រឹងសេវាប្រឹក្សាយោបល់ និងផ្តល់កម្ចីសៀវភៅនៅក្នុងពន្ធនាគារទាំង២៨។
- រៀបចំសកម្មភាពវប្បធម៌ និងសិល្បៈនៅក្នុងពន្ធនាគារ។
- ផ្តល់ការគាំទ្រផ្នែកអប់រំសម្រាប់ថ្នាក់អក្ខរកម្ម។
- សម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលការងារ និងពន្ធនាគារ ដើម្បីពង្រឹងកម្មវិធីនៃការរៀបចំសម្រាប់សមាហរណកម្មរបស់ជនជាប់ឃុំ។
- បំពាក់ NomadLab នៅក្នុងពន្ធនាគារចំនួន១០ និងបណ្តុះបណ្តាលមន្ត្រី និងជនជាប់ឃុំអំពីរបៀបប្រើប្រាស់។
- រៀបចំសិក្ខាសាលាស្តីពីកម្មវិធីអប់រំឌីជីថលមិនភ្ជាប់អ៊ីនធឺណិត និងការប្រើប្រាស់ NomadLabs។

# កម្មវិធីអភិវឌ្ឍន៍យុវជន

## បណ្ណាល័យ-ជ្រុងតម្រង់ទិសវិជ្ជាជីវៈ

- បង្កើតបណ្ណាល័យ និងជ្រុងតម្រង់ទិសវិជ្ជាជីវៈថ្មីចំនួនប្រាំពីរ ដែលបំពាក់ដោយ NomadLab។
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងការសម្របសម្រួលបណ្ណាល័យ និងលើការតម្រង់ទិសវិជ្ជាជីវៈ សម្រាប់បណ្ណារក្ស ទីប្រឹក្សាណែនាំ គណៈកម្មាធិការគ្រប់គ្រងសាលា និងមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ។
- រៀបចំសិក្ខាសាលាផ្លាស់ប្តូរជំនាញរវាងបណ្ណារក្ស។
- រៀបចំវេទិកាការងារដោយផ្ទាល់ ឬតាមអ៊ីនធឺណិត នៅវិទ្យាល័យ និងអនុវិទ្យាល័យចំនួន១៦។

## ភាពជាពលរដ្ឋសកម្មរបស់យុវជននៅមូលដ្ឋាន

- បំពាក់ Nomad lab នៅតាមអង្គការសហគមនយុវជន៍មូលដ្ឋានចំនួន៨។
- រៀបចំវគ្គបណ្តុះបណ្តាលដល់សមាជិកអង្គការសហគមនយុវជន៍មូលដ្ឋាន ៖ ភាពជាអ្នកដឹកនាំ ការបង្រៀន និងការអាន ការគ្រប់គ្រងថវិកា និងការរៃអង្គាសថវិកា។
- រៀបចំសិក្ខាសាលាស្តីពីឱកាសសិក្សា និងអាហារូបករណ៍សម្រាប់សមាជិកអង្គការសហគមន៍យុវជនមូលដ្ឋាន។
- រៀបចំវគ្គបណ្តុះបណ្តាលមុនចេញដំណើរសម្រាប់អ្នកស្ម័គ្រចិត្តថ្មីរបស់អង្គការយុវតារា។
- គាំទ្រអង្គការសហគមន៍យុវជនមូលដ្ឋានឯករាជ្យចំនួន១១ ក្នុងការគ្រប់គ្រង និងការផ្សព្វផ្សាយបណ្ណាល័យ-ជ្រុងតម្រង់ទិស។
- តាមដាន និងគាំទ្រសកម្មភាពអប់រំ និងការលើកកម្ពស់ការយល់ដឹងដែលធ្វើឡើងនៅក្នុងភូមិដោយសមាជិកនៃអង្គការសហគមន៍យុវជនមូលដ្ឋានទាំង២៣។

## ផលិតឧបករណ៍ថ្មីៗ ជាទម្រង់សៀវភៅ និងឌីជីថល

- វិភាគតម្រូវការរបស់យុវជនក្នុងការតម្រង់ទិស និងការអភិវឌ្ឍខ្លួន។
- ផលិតសៀវភៅចំនួនប្រាំក្បាលអំពីការតម្រង់ទិស និងការណែនាំអំពីការអភិវឌ្ឍខ្លួន។
- រចនា និងដាក់ឱ្យប្រើប្រាស់ឧបករណ៍ឌីជីថលចំនួនបួន នៅក្នុង NomadLabs។
- ចែកចាយសម្ភារៈបោះពុម្ពនៅតាមសាលារៀន។

# កម្មវិធីបោះពុម្ពផ្សាយ

- បោះពុម្ពចំណងជើងថ្មីចំនួន ២៤ និងបោះពុម្ពឡើងវិញ ៨០ ចំណងជើងដែលមានស្រាប់។
- បោះពុម្ពសៀវភៅថ្មីៗ និងស្អាតៗដោយផ្តោតលើសិល្បៈ ( ទាំងពណ៌ និងសខ្មៅ)។
- បង្កើតចំណងជើងថ្មីក្នុងក្រុមសៀវភៅ Montessori ដើម្បីទាក់ទាញកុមារ។
- អភិវឌ្ឍសៀវភៅឆាករូបភាពសម្រាប់យុវវ័យ។
- បង្កើតសៀវភៅអភិវឌ្ឍន៍ខ្លួនសម្រាប់យុវវ័យ។




អង្គការស៊ីប៉ានៅបារាំង

16 rue Champ Lagarde
78000 Versailles

+33 (0)1 39 02 32 52

អង្គការស៊ីប៉ានៅកម្ពុជា

#១៤៨ មហាវិថីព្រះនរោត្តម
ប្រអប់សំបុត្រ ៣១ ភ្នំពេញ

+៨៥៥ (០)១០ ២០០ ៧៤០



សិទ្ធិរូបថត ៖ Florent de Warren / Sipar
គំរូបាយការណ៍រចនាដោយ ៖ Mathieu Mazin


Sipar

www.sipar.org

www.sipar-books.com